សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ខាត់ ស្រីធីម**
លោក **ឃឿន ឃាង**

ណែនាំដោយ
លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២៣**

ឆ្នាំចូលសិក្សា **២០១៩**
ឆ្នាំសរសេរសារណា **២០២៣**

# សេចក្ដីថ្លែងអំណរគុណ


យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ខាត់ ស្រីធីម** និង **យឿន យាខ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩ - ២០២៣ ជំនាន់ទី២៣។

**យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក** និង **អ្នកម្ដាយ** ជាទីគោរព ដែលលោកទាំងពីរមាននូវមហាឧបការគុណដ៏ឧត្តុង្គឧត្ដម និងធំធេងបំផុត គ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណបានផ្ដល់នូវកំណើតចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ភាពកក់ក្ដៅដល់រូបកូន ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូន ចាប់តាំងពីថ្ងៃដែលកូននៅក្នុងផ្ទៃម្ដាយរហូតដល់ពេញវ័យ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ លោកអ្នកមានគុណទាំងពីរបានអប់រំណែនាំ ទូន្មានប្រៀនប្រដៅកូនឱ្យចេះដឹងល្អខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម ដែលពោរពេញទៅដោយចិត្តមេត្តា សណ្ដោះប្រណីដល់រូបកូនទាំងពីរ ព្រមទាំងលោកទាំងពីរបានជំរុញទឹកចិត្តឱ្យកូនខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ដោយបានបញ្ជូនកូនទៅរៀននៅសាលារៀន ព្រមទាំងឧបត្ថម្ភកូន គ្រប់បែបយ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត និងសម្ភារៈរហូតដល់កូនបានបញ្ចប់ការសិក្សានេះដោយទទួលបានជោគជ័យ។ សូមជូនពរលោកទាំងពីរ ដែលជាអ្នកមានគុណ មានសុខភាពល្អ អាយុយឺនយូរ ជៀសផុតពីជម្ងឺ។

យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សាការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង បង្ហាត់បង្រៀន និងចែករំលែកចំណេះដឹងជូនសិស្សនិស្សិតកន្លងមក។

សូមថ្លែងអំណរគុណ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យដឹកនាំ ដោយបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងផ្ដល់ជាគំនិតក្នុងការជួយ ដោយអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំគ្រប់គ្រងជួយសម្រួលយ៉ាងយកចិត្តទុកដាក់ រហូតដល់សារណានេះបានលេចចេញជារូបរាង។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្ដែងសេចក្ដីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរជាពិសេសសូមប្រសិទ្ធពរជ័យសិរីសួស្ដី វិបុលសុខបវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់ក្នុងដៃនេះគឺជាវណ្ណៈកម្មរបស់ពួកយើងខ្ញុំជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលពួកយើងខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវឡើង ដើម្បីទុកជាស្នាដៃសម្រាប់លោកអ្នក។ ពួកយើងខ្ញុំបានព្យាយាមស្រាវជ្រាវនេះឡើងដោយពួកយើងខ្ញុំបានសម្រេចចិត្ត ក្នុងការជ្រើសរើសយកការសរសេរសារណាបញ្ចប់ការសិក្សា ជំនួសការប្រឡងចេញវិញ។ ការសរសេរសារណា យើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ សរសេរឡើង ជាសមិទ្ធិផលមួយក្នុងការចែករំលែកចំណេះដឹង។

យើងខ្ញុំបានជ្រើសរើសប្រធានបទ **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** នេះឡើង ពីព្រោះយើងខ្ញុំបានសិក្សាស្រាវជ្រាវ ដោយមានការយកចិត្តទុកដាក់ និងមានចិត្តចង់យល់ចង់ដឹងបន្ថែមអំពីការទទួលខុសត្រូវរបស់អនីតិជន ដើម្បីទុកជាស្នាដៃ ប្រកបដោយការព្យាយាមពីពួកយើងខ្ញុំ ដើម្បីទុកឱ្យប្អូនៗជំនាន់ក្រោយបានធ្វើការសិក្សាបន្ថែម និងសម្រាប់ការរៀនសូត្រ។ ទោះជានៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សា យើងខ្ញុំបានខិតខំពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយ ក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗ ដោយជាអចេតនាជាពុំខាន។ ការចងក្រងឡើងនូវពាក្យពេចន៍ សម្ដីសំដៅ អត្ថបទប្រាកដជាមានការឆ្គាំឆ្គងឃ្លៀងឃ្លាតជាមិនខាន ដូចជាមានសុភាសិតមួយបានពោលថា **ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច**។ ដូច្នេះយើងខ្ញុំសូមអភ័យទោសពី សំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ អ្នកអាន ដោយការគោរព ស្មោះត្រង់ពីពួកយើងខ្ញុំនូវរាល់កំហុសខុសឆ្គងទាំងឡាយណាដែលអាចកើតចេញដោយអចេតនា និងសូមខន្តីអភ័យទោសដោយការគោរព ហើយយើងខ្ញុំទទួលស្វាគមន៍ក្នុងការរិះគន់បែបស្ថាបនាដើម្បីកែលម្អបន្ថែមនូវមតិយោបល់ដើម្បីទទួលបាននូវកិច្ចការសារណាបញ្ចប់ការសិក្សាមួយដ៏ល្អ។

ជាចុងក្រោយយើងខ្ញុំជានិស្សិតនីតិសាស្ត្រ ជំនាន់ទី**២៣** ឆ្នាំសិក្សា **២០២២-២០២៣** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំមានចិត្តសប្បាយរីករាយ ក្នុងការយកប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវឡើង ដើម្បីជាចំណងដៃសម្រាប់សាលា មិត្តអ្នកអាន និងខ្លួនឯងផ្ទាល់។ ហើយពួកយើងខ្ញុំសូមប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ សិស្សនិស្សិត សាស្ត្រាចារ្យ ជួបប្រទះនូវពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ ការទទួលខុសត្រូវរបស់អនីតិជន** ........ ៣

១.១. បញ្ញត្តិទូទៅ និងលក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ........ ៣

១.១.១. គោលការណ៍មូលដ្ឋាន និងសិទ្ធជាមូលដ្ឋានរបស់អនីតិជន ........ ៣

១.១.១.១. គោលការណ៍មូលដ្ឋាន ........ ៣

១.១.១.២. សិទ្ធិមូលដ្ឋានក្នុងនីតិវិធី ........ ៤

១.១.២. លក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ........ ៥

១.១.២.១. លក្ខខណ្ឌអាយុក្រោម១៤(ដប់បួន)ឆ្នាំ ........ ៦

១.១.២.២. លក្ខខណ្ឌអាយុ១៤(ដប់បួន)ឆ្នាំដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ ........ ៧

១.២. កាលៈទេសៈនៃបទល្មើស និង បុគ្គលិកលក្ខណៈ ........ ៨

១.២.១. កាលៈទេសៈនៃបទល្មើស ........ ៨

១.២.២. បុគ្គលិកលក្ខណៈរបស់អនីតិជន ........ ៩

**ជំពូកទី២៖ វិធានការ និងលំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន** ........ ១០

២.១. វិធានការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ........ ១០

២.១.១. វិធានការទណ្ឌកម្មព្រហ្មទណ្ឌ ........ ១០

២.១.១.១. ទោសដែលអាចអនុវត្តបានចំពោះអនីតិជន ........ ១០

២.១.១.២. ស្ថានភាពសម្រាលទោសចំពោះអនីតិជន ........ ១៤

២.១.២. វិធានការបង្វែរ ........ ១៦

២.១.២.១. លក្ខខណ្ឌនៃការបង្វែរ ........ ១៦

២.១.២.២. ការអនុវត្តនូវផែនការបង្វែរ ........ ១៨

២.២. លំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន ........ ១៩

២.២.១. នីតិវិធីនៃការស៊ើបអង្កេត និងចំណាត់ការសំណុំរឿង ........ ១៩

២.២.១.១. ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ១៩

២.២.១.២. ចំណាត់ការសំណុំរឿងដោយអយ្យការ ............ ២៣
២.២.២. នីតិវិធីនៃការស៊ើបសួរ និងការជំនុំជម្រះ............ ២៤
២.២.២.១. ការស៊ើបសួរធ្វើឡើងវិញដោយចៅក្រមស៊ើបសួរ............ ២៥
២.២.២.២. ការជំនុំជម្រះ ............ ២៧
**ជំពូកទី៣៖ ការអនុវត្តទោសព្រហ្មទណ្ឌចំពោះអនីតិជន**............ ២៩
៣.១. ការអនុវត្តទោសចំពោះអនីតិជន ............ ២៩
៣.១.១. ការអនុវត្តទោសដាក់ពន្ធនាគារ ............ ២៩
៣.១.២. ការអនុវត្តទោសពិន័យ............ ៣១
៣.១.៣. ការអនុវត្តទោសក្នុងមណ្ឌលឃុំវនីតិសម្បទា ............ ៣៣
៣.២. ការដោះលែងដោយមានលក្ខខណ្ឌ ............ ៣៦
៣.២.១. ការដោះលែងដោយផ្អែកលើអត្តចរឹក ............ ៣៦
៣.២.២. ការដោះលែងដោយផ្អែកលើតាមការស្នើសុំ............ ៣៦
៣.៣. ការស្តានីតិសម្បទាឡើងវិញ ............ ៣៧
៣.៣.១. ការស្តារនីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ............ ៣៧
៣.៣.២. ការស្តារនីតិសម្បទាឡើងវិញតាមច្បាប់កំណត់ ............ ៣៨
**សេចក្តីសន្និដ្ឋាន** ............ ៣៩
**អនុសាសន៍** ............ ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមមួយ ច្បាស់ណាស់អំពើអស្ថិរភាព អសន្តិសុខឬភាពវឹកវរ តែងតែកើតមានឡើងដែលបង្កឲ្យប៉ះពាល់ដល់សង្គមជាតិ។ ជាគោលការណ៍ទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌ នៅពេលមានបទល្មើសមួយបានកើតឡើង ត្រូវតែមានបុគ្គលណាម្នាក់ជាអ្នកទទួលខុសត្រូវចំពោះបទល្មើសនោះ។ នេះជាមូលហេតុដែលញ៉ាំងឲ្យច្បាប់ត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងសកម្មភាពនានារបស់មនុស្ស ទោះបីជាពួកគេមានសិទ្ធិសេរីភាពពេញលេញក៏ដោយ ប៉ុន្តែការប្រើប្រាស់សិទ្ធិនេះត្រូវស្របតាមការចែងរបស់រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗទៀតពោល គឺពលរដ្ឋពុំអាចធ្វើអ្វីតាមតែទំនើងចិត្ត និងហួសព្រំដែនកំណត់នៃច្បាប់ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ និងសង្គមជាតិឡើយ។ បុគ្គលដែលប្រព្រឹត្តបទល្មើសជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលរូបវន្តបុគ្គលសំដៅទៅលើនីតិជន និងអនីតិជន។ នីតិជនសំដៅទៅលើជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ចំណែកឯអនីតិជន សំដៅទៅលើជនដែលមានអាយុតិចជាង១៨ឆ្នាំ នៅពេលជននេះបានប្រព្រឹត្តបទល្មើស។

ជាការពិតណាស់ បុគ្គលដែលប្រព្រឹត្តបទល្មើសពុំអាចរួចផុតពីសំណាញ់ច្បាប់នោះឡើយ ប៉ុន្តែដោយឡែកបើយើងក្រឡេកទៅមើលករណីពិសេសមួយគឺ អនីតិជនដែលបានប្រព្រឹត្តបទល្មើសហើយ បែរជាអាចរួចផុតពីការទទួលខុសត្រូវនៃព្រហ្មទណ្ឌ ឬទទួលការខុសត្រូវក្នុងកម្រិតណាមួយកំណត់ដោយច្បាប់ខុសពីរូបវន្តបុគ្គលជានីតិជន ព្រោះថាអនីតិជនមានសិទ្ធិពិសេស ទទួលបានការការពារដោយច្បាប់ ហើយ "**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**" នោះត្រូវបានយកមកសំអាងក្នុងការកំណត់សិទ្ធិជាមូលដ្ឋាន កំណត់នីតិភាពនៃការទទួលខុសត្រូវ និងនីតិវិធីអនុវត្តទោសនេះ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដោយមានការសង្កេតឃើញថានីតិជនជាជនដែលមានសមត្ថភាពក្នុងការយល់ដឹងពីអំពើ នៅមានកម្រិតនៅឡើយ ដូច្នេះទើបមានសំនួរចោទជាបញ្ហាឡើងថា តើអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ត្រូវមានវិធានការបែបណា និងត្រូវអនុវត្តទោសយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវ តាក់តែង និងចងក្រងសារណានេះឡើងមក គឺធ្វើឡើងក្នុងគោលបំណងដើម្បីយល់កាន់តែច្បាស់ ក៏ដូចជាស្រាយបំភ្លឺនូវចម្ងល់ និងចំណោទជាបញ្ហាគតិយុត្តិ ដូចដែលបានលើកបង្ហាញខាងលើនេះដែលពាក់ព័ន្ធនឹងអនីតិជន។ លើសពីនេះ ក្នុងការចងក្រងសារណានេះឡើងក៏ដើម្បីបំពេញចន្លោះខ្វះខាតដែលពួកយើងមាន និងពង្រីកពង្រឹងនូវសមត្ថភាពរបស់ពួកយើងបន្ថែមទៀត។ ជាមួយគ្នានេះផងដែរ ការចងក្រងនូវសារណានេះ ក៏សម្រាប់ទុកជាស្នាដៃសម្រាប់ខ្លួនឯង ជាពិសេសនោះគឺសម្រាប់ទុកជូនសិស្សនិសិត្សជំនាន់ក្រោយ

ព្រមទាំងសាធារណៈជនគ្រប់រូបដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រធានបទនេះបន្ថែមទៀត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅ នឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោទខាងលើនេះ សារណានេះត្រូវបានធ្វើការសិក្សាស្រាវជ្រាវលើឯកសារជាមូលដ្ឋានមានដូចជា ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ និងឯកសារបទដ្ឋានគតិយុត្តិទាំងឡាយដែលមានពាក់ព័ន្ធ ដែលបានលើកឡើងក្នុងឯកសារយោងស្រាប់ ដើម្បីសរសេរសារណានេះឡើង។

នៅក្នុងការសរសេរសារណានេះ គឺបានលើកឡើងតែអំពីការពាក់ព័ន្ធទាំងឡាយ ដែលទាក់ទងជាមួយនឹងនីតិវិធីដែលត្រូវយកមកអនុវត្តចំពោះអនីតិជន និងទោសដែលអនីតិជនត្រូវទទួលតែប៉ុណ្ណោះ។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

សារណានេះមានសារៈប្រយោជន៍ជាច្រើនចំពោះអ្នកសិក្សា អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវផ្ទាល់ដោយសារតែ សារណានេះបានវែកញែក បកស្រាយយ៉ាងស៊ីជម្រៅពីការកំណត់នូវវិធាន និងនីតិវិធីនៃការអនុវត្តទោសព្រហ្មទណ្ឌ ទៅលើអនីតិជនដែលបានប្រព្រឹត្តបទល្មើស និងអាចឲ្យបងប្អូននិស្សិតយល់ដឹងអំពីផ្នែកមួយនៃនីតិព្រហ្មទណ្ឌអំពីយុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបចងក្រងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និងវិភាគ។ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយ ធ្វើការប្រមូលព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះដើម្បីឲ្យកាន់តែមានភាពត្រឹមត្រូវច្បាស់លាស់ និងមានប្រសិទ្ធិភាពខ្ពស់។ ព័ត៌មានទាំងឡាយ ដែលបានធ្វើការស្រាវជ្រាវឡើង ដែលជាមូលដ្ឋានគ្រឹះប្រកបដោយសុក្រឹត្យភាព រួមមានការពាក់ព័ន្ធ និងច្បាប់នានា និងពឹងផ្អែកទៅលើការសុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា សុំមតិយោបល់ពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សច្បង ឯកសារបទដ្ឋានគតិយុត្តនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជារួមមកប្រធានបទស្រាវជ្រាវអំពី **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** គឺត្រូវបានបែងចែកជា ០៣ ជំពូកធំៗរួមមាន៖

- **ជំពូកទី១ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**
- **ជំពូកទី២ ៖ វិធានការ និងលំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន**
- **ជំពូកទី៣ ៖ ការអនុវត្តទោសចំពោះអនីតិជន**

# ជំពូកទី១

# ការទទួលខុសត្រូវរបស់

# អតិថិជន

# ជំពូកទី១

# ការទទួលខុសត្រូវរបស់អនីតិជន

## ១.១. បញ្ញត្តិទូទៅ និងលក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

### ១.១.១. គោលការណ៍មូលដ្ឋាន និងសិទ្ធជាមូលដ្ឋានរបស់អនីតិជន

#### ១.១.១.១. គោលការណ៍មូលដ្ឋាន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនភាគច្រើន ផ្តើមចេញជាមួយការចែងអំពីគោលការណ៍ណែនាំ ដែលមានដកស្រង់ចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតុបករណ៍អន្តរជាតិដទៃផ្សេងទៀត ។ កត្តានេះហើយទើបធ្វើឲ្យមានការចែងជាច្បាប់បែបនេះ ក្នុងគោលដៅដើម្បីបញ្ជាក់ឲ្យច្បាស់អំពីរបៀបដែលរដ្ឋ មានវិធានការចំពោះកុមារដែលប្រព្រឹត្តបទល្មើស ហើយវាមានលក្ខណៈ ខុសប្លែកគ្នានូវវិធីសាស្រ្តដាក់ទោស ដែលមានចែងនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ។ គោលការណ៍ ទាំងនេះក៏បានផ្តល់នូវគោលការណ៍ណែនាំដល់ស្ថាប័នតុលាការ និងអាជ្ញាធររដ្ឋបាលផ្សេងៗ នៅពេលដែលអាជ្ញាធរទាំងនោះកំពុងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមច្បាប់កំណត់ ។ ហេតុដូចនេះ ហើយទើបមានបញ្ញត្តិ អំពីគោលការណ៍ដែលទាក់ទងទៅ នឹងឧត្តមប្រយោជន៍របស់កុមារ ដែលមានគោលការណ៍ដូចតទៅ ៖

- គោលការណ៍សមាមាត្រ ដែលដកស្រង់ចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានខ្លឹមសារថា វិធានការឆ្លើយតបណាមួយចំពោះកុមារដែលមានទំនាស់នឹងច្បាប់ត្រូវតែសមាមាត្រ មិនត្រឹមតែប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ប៉ុណ្ណោះទេ តែត្រូវសមាមាត្រជាមួយនឹងកាលៈទេសៈ និងភាពចាស់ទុំរបស់កុមារផងដែរ ។
- បឋមភាពនៃការឆ្លើយតបតាមរយៈការបង្វែរដែលមានខ្លឹមសារ លើកលែងតែផលប្រយោជន៍ជាសាធារណៈដែលតម្រូវឲ្យដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលមិនត្រូវអនុវត្តចំពោះកុមារសោះឡើយប្រសិនបើមានមធ្យោបាយសម្រាប់ប្រើជំនួសក្នុងការដោះស្រាយបញ្ហានោះ ។
- ការចែងអំពីសិទ្ធិកុមារ ដែលមានខ្លឹមសារសំដៅលើសិទ្ធិកុមារក្នុងការទទួលបាននូវកិច្ចការពារពិសេស និងនីតិវិធីទាំងឡាយនៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- សិទ្ធិកុមារ ដែលមានខ្លឹមសារថា កុមារមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី និងបញ្ចេញមតិបុគ្គល ឬការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងៗទៀតដោយមិនរាងចាល និងធ្វើឡើងតែក្នុងករណីពុំ មានការសម្រេចសមស្របផ្សេងទៀត ។

ដូចនេះចំពោះការដាក់ពន្ធនាគារអស់មួយជីវិតការដាក់ទណ្ឌកម្មលើរូបរាងកាយ និងទង្វើ ឬការដាក់ទណ្ឌកម្មឃោឃៅ ឬបន្ទាបបន្ថោកដល់អនីតិជនត្រូវបានហាមឃាត់ ។

### ១.១.១.២. សិទ្ធិមូលដ្ឋានក្នុងនីតិវិធី

រាល់ដំណើរការនៃនីតិវិធីទាំងមូលត្រូវប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ ដោយអនុញ្ញាតឲ្យមានការចូលរួមយ៉ាងពេញលេញ និងមានការសម្តែងមតិដោយសេរីពីសំណាក់អនីតិជន និង ឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់អនីតិជន ។

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាប្រព្រឹត្តបទល្មើស ត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹង អំពីការចាប់ខ្លួនទៅដល់អ្នកតំណាង ដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬ ដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី នៅគ្រប់ដំណើរការរឿងក្តី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ[1]
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តិជាធរមាន ។

គ្រប់ដំណើរការនៃនីតិវិធីទាំងមូល ដែលមានខាងលើនេះត្រូវគោរពនូវសិទ្ធិជីវភាពឯកជន របស់អនីតិជនហើយត្រូវរក្សាទុកកំណត់ហេតុនានានៃរឿងក្តីជាការសម្ងាត់ ដើម្បីនឹងជៀសវាងនូវ ព្យសនកម្ម បណ្តាលមកពីការ

[1] មាត្រា៦ វាក្យខណ្ឌ ១៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ផ្សព្វផ្សាយជាសាធារណៈ ឬ ដោយសារការជេរប្រមាថ។ ហេតុនេះហើយ ការផ្សព្វផ្សាយព័ត៌មាន ដែលទាក់ទងនឹងដំណើរការរឿងក្តីអនីតិជន មិនត្រូវបានឲ្យមានការអនុញ្ញាតនោះទេ លុះត្រាតែមានការអនុញ្ញាតជាមុនពីចៅក្រម ដែលត្រូវបានចាត់តាំងឲ្យកាន់រឿងក្តី។ ការអនុញ្ញាតរបស់អាជ្ញាធរអាចធ្វើទៅបានលុះត្រាតែក្នុងគោលបំណងអប់រំស្រាវជ្រាវ ឬ សិក្សានៅក្នុងបណ្ឌិតសភា ឬ ផលប្រយោជន៍សាធារណៈប្រសិនបើចាំបាច់ ប៉ុន្តែក្នុងករណីដែលមានការអនុញ្ញាតមិនត្រូវឲ្យមានព័ត៌មានណាមួយបានបញ្ចេញ ឬផ្សព្វផ្សាយចេញនូវអត្តសញ្ញាណរបស់អនីតិជននោះឡើយ ។

### ១.១.២. លក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ជាគោលការណ៍ទូទៅ នៅក្នុងក្រមព្រហ្មទណ្ឌ នៅពេលមានបទល្មើសមួយកើតឡើង ទោះអំពើនោះ ប្រព្រឹត្តឡើងដោយចេតនាក្តី ឬ អចេតនាក្តី ដែលជាហេតុបណ្តាលឲ្យមានព្យសនកម្មដល់បុគ្គលដទៃ គឺជាលក្ខខណ្ឌចម្បងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ រីឯនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ ចាប់ពីអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងទៅ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុ ចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ ក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ បានផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ[2]។ ម្យ៉ាងទៀតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬ មិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់ អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាងដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ[3] ។ ការលំបាកក្នុងការកំណត់អាយុពិតរបស់អនីតិជននៅត្រង់ថា មិនទាន់មានវិធីសាស្ត្របញ្ជាក់ពីអាយុ តាមលក្ខណៈវិទ្យាសាស្ត្រ ឬ វេជ្ជសាស្ត្រឲ្យបានត្រឹមត្រូវនៅឡើយ។ សម្រាប់គោលបំណងកំណត់អាយុនៃការទទួលខុសត្រូវ ខាងផ្នែកព្រហ្មទណ្ឌរបស់បុគ្គល ដែលមានអាយុត្រូវជាជនជាប់សង្ស័យនោះ គឺជាអាយុនៅពេលដែលជននោះប្រព្រឹត្តបទល្មើសដែលត្រូវបានចោទដោយយើងយោងទៅតាមភស្តុតាងនៃការកំណត់អាយុរបស់បុគ្គលនោះ ដែលត្រូវផ្តោតទៅលើសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត។ ផ្ទុយទៅវិញប្រសិនបើក្នុងករណីពុំមានឯកសារដែលបានបញ្ជាក់ខាងលើនោះទេ ឬ មានបញ្ហាទាក់ទងនឹងលិខិតយថាភូតឯកសារនោះ ដែលភស្តុតាងនៃអាយុរបស់បុគ្គលរូបនោះ យើងត្រូវធ្វើយ៉ាងណា ប្រើប្រាស់

[2] មាត្រា៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[3] មាត្រា៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

គ្រប់ការស្រាវជ្រាវ តាមរយៈមធ្យោបាយដែលអាចទុកចិត្តបានផ្សេងៗទៀតដូចជា វេជ្ជកោសល្យវិច្ច័យលើកំណត់ត្រាសុខភាព កំណត់ត្រាផ្នែកពេទ្យ កំណត់ត្រាផ្នែកទន្តសាស្ត្រ កំណត់ត្រារបស់សាលារៀន ការស្បថក្នុងការផ្តល់សក្ខីកម្មដោយជនជាសាច់ញាតិ ជាពិសេស គឺពីសំណាក់មន្ត្រី ឃុំ សង្កាត់ សមាជិកសហគមន៍ ជនផ្សេងទៀតដែលស្គាល់អនីតិជន ។ ប៉ុន្តែដោយយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់ថា ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់ជនសង្ស័យ នោះនាំឲ្យមានហេតុផលដែលជឿបានថា ជនជាប់សង្ស័យអនីតិជនមានអាយុតិចជាងអាយុជាក់លាក់ណាមួយ ដែលមានសិទ្ធិទទួលនូវការប្រព្រឹត្តពិសេស ដែលជាការផ្តល់ឱកាសឲ្យអនីតិជនបានអនុវត្តតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់។ ជាមួយគ្នានេះដែរ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌអាយុខាងលើ យើងខ្ញុំធ្វើការបែងចែកអនីតិជនជាពីរប្រភេទគឺ៖ លក្ខខណ្ឌអាយុក្រោម១៤(ដប់បួន)ឆ្នាំ និងលក្ខខណ្ឌអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

### ១.១.២.១. លក្ខខណ្ឌអាយុក្រោម១៤(ដប់បួន)ឆ្នាំ

អនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន)ឆ្នាំ នៅពេលដែលប្រព្រឹត្តបទល្មើសគឺច្បាប់បានកំណត់ថាមិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ការកំណត់កម្រិតអាយុអប្បរមា នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលមានអាយុក្រោមអប្បបរមានេះ កុមារត្រូវបានសន្មតជាមុនថាពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ[4]។ អនីតិជនមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំបានត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តធម៌ត្រូវប្រគល់ជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់[5]។ ក្នុងករណីអនិតិជនមានអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសនោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់ទុកឥតចាត់ការ និង ត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាង ដែលច្បាប់បានកំណត់វិញភ្លាម[6]។ តាមខ្លឹមសារខាងលើនេះ អាចនាំឲ្យគេសន្មតបានថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬ អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ពុំទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍៖ ក្មេងប្រុសអាយុ ១០ (ដប់)ឆ្នាំ ម្នាក់បានយកដំបងទៅវាយក្បាលក្មេងប្រុសម្នាក់ទៀតដែលឈរក្បែរនោះ បណ្តាលឲ្យបែកក្បាលរងរបួសជាដំណំ។ ក្នុងករណីនេះ ក្មេងដែលបានប្រព្រឹត្តបទល្មើសនោះ មិនអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ អាស្រ័យដោយហេតុថាក្មេងនោះនៅមិនទាន់មានការយល់ដឹងខុសត្រូវពីអំពើរបស់ខ្លួននៅឡើយ។

---

[4] មាត្រា១០ នៃអនុសញ្ញាស្តីពីកុមារ

[5] មាត្រា១៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[6] មាត្រា២៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

គួរកត់សម្គាល់ដែរថា អនីតិជនអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកបាននូវការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលបានរារាំងចំពោះការចូលរួមខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្ដីសម្រេចនោះទេ (ការស្ដីបន្ទោស ឬ វិធានការអប់រំ)។

ដូច្នេះ តុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះឲ្យចូលខ្លួនមកកាន់តុលាការបានផងដែរ ក្នុងគោលបំណងដើម្បីប្រកាសសេចក្ដីសម្រេច ដាក់ឲ្យអនុវត្តវិធានការណាមួយ ដែលតុលាការបានធ្វើការសម្រេចលើអនីតិជននោះ។ វិធានការទាំងនោះរួមមាន៖ វិធានការតាមដាន វិធានការការពារ និងវិធានការឧបត្ថម្ភ ឬ ក៏ប្រគល់អនីតិជននោះ ទៅឲ្យសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬ ស្ថាប័នឯកទេស និង អាចដាក់អនីតិជននោះ ឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការបានផងដែរ។

**១.១.២.២. លក្ខខណ្ឌអាយុ១៤(ដប់បួន)ឆ្នាំដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ**

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំវិញ នៅពេលដែលអនីតិជនប្រភេទនេះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ ។ ហេតុដែលច្បាប់តម្រូវឲ្យមានការទទួលខុសត្រូវ ព្រោះយល់ឃើញថា អនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ ។ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចយល់ពីបញ្ហានូវរាល់អំពើទាំងនោះបាន។ ការយល់ឃើញយ៉ាងដូច្នេះ នីតិករបានពិចារណាដោយផ្អែកទៅលើ ការរីកចម្រើនអំពីរូបរាងកាយ ប្រាជ្ញា ស្មារតី និង ការសន្សំនូវបទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅរបស់អនីតិជននោះឯង។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យច្បាប់សន្មតបានថា អនីតិជនប្រភេទនេះអាចពិចារណាយល់ដឹងបានគ្រប់គ្រាន់នូវរាល់ការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចដឹងពីបញ្ហានូវរាល់អំពើរបស់ខ្លួនបានថែមទៀតផង។ ថ្វីត្បិតតែច្បាប់បានតម្រូវឲ្យអនីតិជនប្រភេទនេះ មានការទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានប្រព្រឹត្តក៏ពិតមែន ប៉ុន្តែការទទួលខុសត្រូវនេះ មិនមានលក្ខណៈពេញលេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននេះត្រូវទទួលរងគឺ មានកម្រិតស្រាលជាងនីតិជន។ ហើយដើម្បីអាចសម្រេចបទល្មើសដែលអនីតិជននេះបានប្រព្រឹត្ត និងរួមទាំងបុគ្គលិកលក្ខណៈរបស់អនីតិជនប្រភេទនេះផងដែរ។ ចំពោះទោសដែលត្រូវទទួលរងវិញ គឺអាចមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ឬ អាចហៅបានម៉្យាងទៀតថាមូលទោស។ សូមបញ្ជាក់ថា បើទោះបីជាអនីតិជនអាចទទួលរងនូវទោសបែបនេះក៏ដោយ ក៏នៅកម្រិតនីតិជន។ ជារួមគេអាចយល់បានថា ការបន្ថយទោសចំពោះអនីតិជន អាចបណ្ដាលមកពីមូលហេតុអនីតិភាពនៃទណ្ឌិតនេះឯង។ ចំពោះការផ្ដន្ទាទោសលើអនីតិជនបាន តុលាការត្រូវពិចារណាថ្លឹងថ្លែងជាមុនសិនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃទោសដែលទទួលរង គឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាល បើប្រៀបធៀបទៅនឹងទោសដែល

មានចែងចំពោះ។ ឧទាហរណ៍៖ ក្មេងស្រី ក មានអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ បានឈ្លោះប្រកែកជាមួយក្មេងប្រុស ខ។ នៅពេល ឈ្លោះប្រកែកនោះក្មេងស្រី ក បានជ្រុលដៃចាក់ក្មេងប្រុស ខ មួយកាំបិតចំកញ្ចឹងកបណ្តាលឲ្យស្លាប់។ អំពើដែល ក្មេងស្រី ក បានប្រព្រឹត្តមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ដូច្នេះ ចំពោះទោស ដែលត្រូវ អនុវត្តចំពោះក្មេងស្រីនោះគឺត្រូវបន្ថយមកត្រឹមពាក់កណ្តាលបើធៀបទៅនឹងទោសដែលត្រូវអនុវត្តចំពោះ នីតិជន។

អនីតិជនមិនទាន់ចាត់ទុកថាមានភាពចាស់ទុំ ឬមានការទទួលខុសត្រូវគ្រប់គ្រាន់នឹងវិនិច្ឆ័យលើអំពរបស់ ខ្លួនដូចជាមនុស្សពេញវ័យនោះទេ។

## ១.២. កាលៈទេសៈនៃបទល្មើស និង បុគ្គលិកលក្ខណៈ

យោងតាមគោលការណ៍នៃការកំណត់ទណ្ឌកម្ម ឬគោលការណ៍ក្នុងការកំណត់ការផ្តន្ទាទោស ចៅក្រម អាចផ្តន្ទាទោសជនល្មើសម្នាក់បាន ត្រូវពិចារណាអំពីបាតុភូតសង្គមដែលជាបទល្មើសបានកើតឡើង ឲ្យបាន គ្រប់ជ្រុងជ្រោយជាមុនសិន ទើបធ្វើការសម្រេចផ្តន្ទាទោសទៅលើចារីនោះបាន។ មានន័យថា ដើម្បីអាចចេញនូវ សេចក្តីសម្រេចប្រកបដោយសុក្រិត្យភាព និងសុភវិនិច្ឆ័យ ចៅក្រមត្រូវពិចារណាទៅលើបីចំណុចសំខាន់ៗគឺ

- ត្រូវពិចារណាពាក់ព័ន្ធនឹងបញ្ហាដែលមានចែងនៅក្នុងច្បាប់ ពោលគឺសំដៅទៅដល់គោលការណ៍នីត្យានុកូល នៃទោស។
- ត្រូវពិចារណាទៅលើស្ថានភាពនៃការប្រព្រឹត្តបទល្មើសថា តើបទល្មើសនោះបានប្រព្រឹត្តនៅក្នុងកាលៈទេសៈ ណា? ពេលវេលាណា? ទីកន្លែងណា?
- ត្រូវពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះផងដែរ។ តុលាការអាចដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ដោយផ្តោតលើកាលៈទេសៈ នៃបទល្មើស (១.២.១) ឬបុគ្គលិកលក្ខណៈរបស់អនីតិជន (១.២.២)។

### ១.២.១. កាលៈទេសៈនៃបទល្មើស

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៨ បានកំណត់ថា មានការទទួលខុសត្រូវរបស់ ព្រហ្មទណ្ឌបានលុះត្រាតែមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ដោយហេតុថាអាយុក្រោម ១៨ (ដប់ប្រាំ បី) ឆ្នាំ គឺជាអនីតិជនដូចនេះការយល់ដឹងរបស់ពួកគេនៅមានភាពខ្វះខាតនៅឡើយ តែប្រសិនបើ អនីតិជនបាន ប្រព្រឹត្តបទល្មើសអ្វីមួយនោះ វិធានការអនុវត្តចំពោះអនីតិជនគឺមានតែ វិធានការតាមដាន វិធានការអប់រំ វិធានការ ការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ។ ប៉ុន្តែចំណុចនេះអាចមានការពិបាក ដោយហេតុថា ក្នុងករណីដែល មានអនីតិជនអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទល្មើសដែលមានទម្ងន់ទោសធ្ងន់ធ្ងរណាមួយ។ ប៉ុន្តែនៅ ក្នុងមាត្រា ៣៩ កថាខណ្ឌទី២ បានបញ្ញត្តិបន្ថែមថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន

អាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[7]។ មានន័យថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ឲ្យបានច្បាស់លាស់នូវឡើយ អំពីពាក្យថាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនិតិជន។ ដូចនេះនៅពេលជួបប្រទះករណីណាមួយ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការ ដែលគេហៅម៉្យាងទៀតថា ឆន្ទានុសិទ្ធិក្នុងការគិតពិចារណាថា តើអនីតិជននោះត្រូវទទួលខុសត្រូវ ឬក៏អត់ចំពោះទង្វើល្មើសច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។

**១.២.២. បុគ្គលិកលក្ខណៈរបស់អនីតិជន**

ជាទូទៅរាល់អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសទាំងអស់ តុលាការអាចសម្រេចដាក់ត្រឹមតែវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះដែលមានដូចជា[8]៖

ក. ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងទំនុកចិត្ត។

ខ. ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

គ. ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទានៅក្នុងការទទួលអនីតិជន។

ឃ. ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។

៥. ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការពាររបស់តុលាការ ត្រង់ចំណុចនេះមានន័យថា តុលាការត្រូវចាត់តាំងបុគ្គលណាមួយរូប ដែលទទួលភារៈធ្វើការតាមដានអនីតិជន បុគ្គលនេះត្រូវធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ ការកំណត់បុគ្គលិកលក្ខណៈរបស់ជនល្មើស យើងអាចកំណត់បានតាមរយៈរបបវេជ្ជសាស្ត្រ និងរបបតាមបែបធម្មជាតិ។ ក៏ប៉ុន្តែ ចំពោះអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលមានស្ថានទម្ងន់ធ្ងន់ធ្ងរ តុលាការអាចសម្រេចផ្តន្ទាទោសអនីតិជន ដោយបន្ថយពាក់កណ្តាលនៃទោសដែលអនុវត្តចំពោះនីតិជន។

---

[7] មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[8] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

# ជំពូកទី២

# វិធានការ និងលំហូរនីតិ
# វិធីដែលត្រូវអនុវត្ត
# ចំពោះអនីតិជន

# ជំពូកទី២

# វិធានការ និងលំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន

## ២.១. វិធានការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

អនីតិជនដែលបានប្រព្រឹត្តបទល្មើស ហើយដែលគេជឿជាក់ថាបានប្រព្រឹត្តបទល្មើស វិធានការជាទូទៅដែលត្រូវបានលើកយកមកអនុវត្តចំពោះអនីតិជននោះរួមមាន វិធានការទណ្ឌកម្ម ព្រហ្មទណ្ឌ (២.១.១) និងវិធានការបង្វែរ (២.១.២) ។ ដោយឡែក វិធានការទណ្ឌកម្មព្រហ្មទណ្ឌ ត្រូវតែជា វិធានការចុងក្រោយបំផុត សម្រាប់លើកយកមកអនុវត្តចំពោះអនីតិជន។

### ២.១.១. វិធានការទណ្ឌកម្មព្រហ្មទណ្ឌ

អនីតិជនក៏អាចទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ ដូចនីតិជនផងដែរ។ ក៏ប៉ុន្តែអ្វីដែលខុសគ្នានោះ នៅត្រង់ថា របបនៃទោសដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន គឺមិនដូចគ្នាទៅនឹងរបបនៃទោសដែលអនុវត្តចំពោះនីតិជនឡើយ ពោលគឺអនីតិជនមាននូវរបបគតិយុត្តពិសេសមួយ ដាច់ដោយឡែកពីនីតិជន។ ជាងនេះទៅទៀត ដោយហេតុថាអនីតិជនមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិតនៅឡើយ កាលបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ តុលាការក៏អាចសម្រេចឲ្យអនីតិជនទទួលបាននូវការសម្រាលទោសផងដែរ។ ជាមួយគ្នានេះ របបនៃទោសដែលអាចលើកយកមកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ ៖

#### ២.១.១.១. ទោសដែលអាចអនុវត្តបានចំពោះអនីតិជន

ទោសដែលអាចអនុវត្តបានចំពោះអនីតិជន មានទ្រឹស្តីជាច្រើន ដែលកំណត់អំពីប្រភេទនៃទោសខុសៗគ្នានៅលើសាកលលោកយើង ហើយទោសព្រហ្មទណ្ឌនេះទៀតសោតធន់ គឺមានការបែងចែកជាច្រើនប្រភេទទៅតាមនោះ។ ប្រទេសនីមួយៗប្រកាន់យកនូវប្រព័ន្ធច្បាប់ ឬគោលការណ៍ផ្សេងៗគ្នា។ គេសង្កេតឃើញថា ទោសនេះ គឺមានភាពប្រែប្រួលទៅតាមបុគ្គលដែលបានប្រព្រឹត្តបទល្មើសផងដែរ។ ការប្រែប្រួលនេះ នាំឲ្យគេយល់បានថា អាចបណ្តាលមកពីមូលហេតុនៃការវិវត្តរបស់ជនល្មើសនៅក្នុងសង្គម ឧក្រិដ្ឋកម្មនេះឯង។ ដោយឡែក ផ្អែកទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យក និងធ្វើការបែងចែកប្រភេទនៃទោសជា បីប្រភេទគឺ៖

**មូលទោស** គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះ ជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោស ត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌ រួមមានទោសដាក់ពន្ធនាគារ និង

ទោសពិន័យជាប្រាក់[9]។ ក្នុងករណីនេះដែរ ប្រសិនបើអនីតិជនម្នាក់ ដែលមានអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ចៅក្រមបានពិនិត្យនិងពិចារណាទៅលើ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជន នោះឃើញថា មានលក្ខណៈតម្រូវគ្រប់គ្រាន់ហើយ ដូចនេះច្បាប់បានផ្តល់នូវឆន្ទានុសិតដល់ចៅក្រមអាចប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះបាន។

គួរកត់ចំណាំថា ក្នុងករណីដែលចៅក្រមសម្រេចយ៉ាងដូច្នេះ គឺជាជម្រើសចុងក្រោយបំផុត ហើយដោយហេតុថា ស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជននោះ ច្បាស់ណាស់ថាប្រាកដជាមានលក្ខណៈសាហាវព្រៃផ្សៃខ្លាំងណាស់ហើយ ឬក៏អាចជាហេតុដែលនាំឲ្យមានការប៉ះពាល់ដល់សង្គមធ្ងន់ធ្ងរណាស់ ទើបធ្វើការសម្រេចយ៉ាងដូច្នេះ ។

ឧទាហរណ៍ ៖ អនីតិជនម្នាក់បានប្រព្រឹត្តនូវបទឧក្រិដ្ឋមួយដែលមានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សង្គម ពោលគឺគាត់បានជិះម៉ូតូឆក់កាបូបរបស់ជនរងគ្រោះតាមផ្លូវ បណ្តាលឲ្យជនរងគ្រោះដួលបោកក្បាលស្លាប់ភ្លាមៗនៅហ្នឹងកន្លែង។ ករណីបែបនេះ គឺប្រហែលជាមិនអាចប្រើប្រាស់នូវវិធានការផ្សេងក្រៅពីទោសលើរូបគាត់ឡើយ ហេតុនេះជម្រើសដ៏សមគួរបំផុតនោះ គឺច្បាប់ត្រូវផ្តន្ទាទោសព្រហ្មទណ្ឌលើរូបគាត់ ហើយទើបអាចរក្សានូវសណ្តាប់សង្គម និងធ្វើឲ្យសង្គមមាននូវរបៀបរៀបរយទៅបាន ។

ដូច្នេះសម្រាប់មូលទោសដែលអនុវត្តចំពោះអនីតិជន ក៏ច្បាប់បានកំណត់នៅក្នុងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ បានចែងអំពីមូលទោសដែលអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ។ កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលត្រូវចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅៈ

ក- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

ឧទាហរណ៍ ៖ ប្រសិនបើអនុវត្តចំពោះមនុស្សពេញវ័យវិញ ទោសដែលត្រូវទទួលរង គឺ ២០ ឆ្នាំ ប៉ុន្តែចំពោះអនីតិជនវិញត្រូវទទួលរងជាអតិបរមាត្រឹមតែ ១០ ឆ្នាំ ប៉ុណ្ណោះ ។

ខ- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

គ- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះ លើសពី ១ (មួយ) ថ្ងៃ ។

[9] មាត្រា៤៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

ឧទាហរណ៍ ៖ ក្នុងករណីដែលទោសជាប់ពន្ធនាគារ ដែលត្រូវទទួលរងគឺ ៤ ថ្ងៃអប្បបរមា ចំពោះបទលហុ អនីតិជននឹងត្រូវទទួលរងគឺ ២ ថ្ងៃជាអប្បបរមា ។

ឃ- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ឧទាហរណ៍ ៖ ប្រសិនបើទោសពិន័យដែលត្រូវទទួលរងគឺនៅចន្លោះពី ២០០០.០០០ និង ៦.០០០.០០០ រៀល ចំពោះអនីតិជនត្រូវទទួលរងត្រឹមតែពិន័យពីចន្លោះ១ ០០០ ០០០ រៀល និង ៣ ០០០ ០០០ រៀល ។ ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយ អតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើស ដែលចោទប្រកាន់នោះគឺនៅតែជាបទឧក្រិដ្ឋដដែល ។

សូមបញ្ជាក់ថា នេះគ្រាន់តែជាការរំលឹកនូវវិធានដែលចែងថា ប្រភេទនៃបទល្មើសពុំកែប្រែ ដោយការបន្ថយស្របច្បាប់នូវទោសជាប់ពន្ធនាគារ ដែលអនុវត្តចំពោះអនីតិជនឡើយ។ បើយើងពិនិត្យមើលទៅលើមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ត្រង់ចំណុចទីពីរ បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ចំពោះបទឧក្រិដ្ឋទោសជាប់ពន្ធនាគារ ដែលត្រូវទទួលរង គឺមានរយៈពេលលើសពី ៥ ឆ្នាំ។ ដូច្នេះ ដោយហេតុថាមានការបន្ធូរបន្ថយស្របច្បាប់ដែលបានចែងជាប្រយោជន៍ដល់អនីតិជន ប្រសិនបើទោសដែលទទួលរងដោយអនីតិជនចំពោះបទឧក្រិដ្ឋ បែជាតិចជាង ៥ ឆ្នាំទៅវិញនោះ ពុំត្រូវបានផ្លាស់ប្តូរប្រភេទគតិយុត្តដើម ជាបទឧក្រិដ្ឋនៃបទល្មើសឡើយ ។

គប្បីពិចារណាផងដែរថា ទោះបីជាអនីតិជនដែលមានអាយុលើសពី ១៤ ឆ្នាំហើយក៏ដោយ ក៏តុលាការគួរតែអនុគ្រោះដល់ការប្រកាសនូវវិធានការ ឧបត្ថម្ភ អប់រំ និងការពារ ជាអាទិ៍ ដើម្បីបានជាប្រយោជន៍ជូនទៅដល់អនីតិជននោះផងដែរ។ ជាជាងការដាក់នូវទណ្ឌកម្មបង្ក្រាប ដើម្បីជៀសវាងនូវការដាក់ពន្ធនាគារ ដែរជាញឹកញាប់ក្លាយទៅជាប្រភពនៃគ្រោះថ្នាក់កាន់តែកើនឡើងចំពោះអនីតិជនដែលជួបជាមួយអ្នកជាប់ឃុំឃាំងផ្សេងៗទៀត ដែលជួនកាលមានសភាពគ្រោះថ្នាក់ជាងនេះទៅទៀតផងក៏អាចថាបាន។ ក្រៅអំពីទោសដែលជាមូលដ្ឋាន តុលាការក៏អាចធ្វើការសម្រេចពិចារណា អំពីទោសបន្ថែម ដែលអាចប្រកាសចំពោះទណ្ឌិតជាអនីតិជននោះបានថែមទៀតផងដែរ។

**ទោសបន្ថែម** គឺសំដៅដល់ប្រភេទទោសមួយ ដែលបន្ថែមទៅលើមូលទោស។ មានន័យថា ជាទូទៅនៅពេលដែលចៅក្រមប្រកាសអំពីមូលទោស ហើយក្នុងករណីដែលលក្ខខណ្ឌច្បាប់ចែងកំណត់ថា អនុញ្ញាតឲ្យមានការផ្តន្ទាទោសបន្ថែមទៀតនោះ ចៅក្រមអាចសម្រេចទោសបន្ថែមនេះ ដើម្បីបន្ថែមទៅលើមូលទោសនោះទៀតបាន។ បើពិនិត្យទៅលើបច្ចេកទេសនៅក្នុងការអនុវត្តទោសបន្ថែមចំពោះទណ្ឌិតជាអនីតិជននេះ គឺមិនមានលក្ខណៈអ្វីខុសប្លែកពីការអនុវត្តទោសបន្ថែម ចំពោះនីតិជនឡើយ ។ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺនៅត្រង់ថា ទោសបន្ថែមដែលអាចអនុវត្តចំពោះ អនីតិជនបានគឺមានត្រឹមតែចំនួន ៥ ចំណុចតែប៉ុណ្ណោះ ខុសពីទោសបន្ថែមដែលអនុវត្ត

ចំពោះនីតិជន គឺមានរហូតទៅដល់ ១៩ ចំណុចឯណោះ។ យោងតាមក្រមព្រហ្មទណ្ឌ ត្រង់បញ្ញត្តិនៃមាត្រាទោសបន្ថែម គឺសំដៅដល់ប្រភេទទោសមួយ ដែលបន្ថែមទៅលើមូលទោស។ មានន័យថា ១៦១ បានចែងអំពីទោសដែលអាចលើកយកមកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ[10] ៖

ក. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែល មានគោលដៅប្រព្រឹត្តបទល្មើស ។

ខ. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

គ. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

ឃ. ការរឹបអូសឧបកណ៍ភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបាន ប្រព្រឹត្ត ។

ង. ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ គ្រប់ប្រភេទ ។

ដូច្នេះ មានតែទោសបន្ថែមត្រឹមតែ ៥ ដូចដែលបានរៀបរាប់ខាងលើនេះតែប៉ុណ្ណោះ ដែលអាចអនុវត្តបានចំពោះអនីតិជន។ ហើយក្នុងចំណោមទោសបន្ថែមទាំងនេះមានទោសបន្ថែមទី ៤ គឺជាវិធានការរឹបអូសនូវទ្រព្យសម្បត្តិ ដែលមានទំនាក់ទំនងជាមួយនឹងបទល្មើស ចំណែកឯទោស បន្ថែមទី ៥ វិញគឺគ្រាន់តែជាការហាមឃាត់មិនធ្វើការកាន់កាប់ ឬ ប្រដាប់អាវុធតែប៉ុណ្ណោះ ។ សូមបញ្ជាក់ថា ទោសបន្ថែមទាំងនេះ គឺគ្រាន់តែជាវិធានការប្រាតិភោគតែប៉ុណ្ណោះ ហើយមាននូវវត្ថុបំណងផ្តល់បុព្វសិទ្ធដល់ទិដ្ឋភាពអប់រំ ជាជាងទិដ្ឋភាពបង្ក្រាប ។

ដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ ក៏ដូចជាអនីតិភាពនៃជនល្មើស ចៅក្រមអាចពិនិត្យពិចារណាទៅលើស្ថានភាព និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីជៀសវាងការអនុវត្តទោសដែលជាមូលដ្ឋានដោយយកទោសការងារសហគមន៍មកអនុវត្តចំពោះអនីតិជនវិញ។

**ការងារសហគមន៍** គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀតដល់សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល[11] ។ ដោយឡែក ទោសការងារសហគមន៍ដែលអនុវត្តចំពោះអនីតិជននេះ គឺមានលក្ខណៈខុសប្លែកគ្នាពីទោសការងារសហគមន៍ ដែលអនុវត្តចំពោះនីតិជនដូចដែលបានលើកឡើងខាងលើនេះ។ អាស្រ័យដោយហេតុថា លក្ខខណ្ឌដែលអាចលើកយកទោសការងារសហគមន៍មកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ ៖

ទី១. លក្ខខណ្ឌអាយុ លុះត្រាតែអនីតិជននោះមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ទើបអាចលើកយកមកអនុវត្តបាន (អនុសញ្ញាអន្តរជាតិ ស្តីពីនីតិការងារ) ។

[10] មាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[11] មាត្រា៧២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

ទី២. ចំពោះថិរវេលាដែលអាចអនុវត្តគឺមិនឲ្យលើសពី ១០០ ម៉ោង នោះទេ មានន័យថា ថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជននេះ គឺច្បាប់បានកំណត់ ត្រឹមតែពាក់កណ្តាលនៃថិរវេលាដែលត្រូវអនុវត្តចំពោះនីតិជនតែប៉ុណ្ណោះ។ ដូច្នេះ ថិរវេលានេះត្រូវ កំរិតមកនៅត្រឹមអប្បបរមាចំនួនមួយរយម៉ោង ដែលតិចជាងបីសប្តាហ៍នៃការមិនទទួលកម្រៃ ។

ទី៣. ត្រូវតែសម្របសម្រួលទៅលើអនីតិជន ពោលគឺសំដៅទៅលើស្ថានភាពដែលទាក់ទងនឹងការជ្រើសរើសការងារមួយដ៏សមស្របសម្រាប់អនីតិជន ដែលមានលក្ខណៈជាការបណ្តុះបណ្តាល ការកែប្រែ ការអប់រំ និងសម្រួលដល់ការបញ្ចូលខ្លួន ឲ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ ។ ហេតុដូច្នេះហើយ លក្ខខណ្ឌដែលទាក់ទងទៅនឹងទោសការងារសហគមន៍ចំពោះអនីតិជននេះ គឺត្រូវមានការគិតគូរពិចារណាជាពិសេសទៅដល់កន្លែងធ្វើការដែលមានលក្ខណៈជាការបណ្តុះបណ្តាល ដើម្បីឲ្យជននោះអាចបានរៀនសូត្រ អប់រំ និងធ្វើការកែប្រែខ្លួនដើម្បីអាចចូលមករស់ នៅក្នុងសង្គមដូចដើមវិញ ឬ ក៏ធ្វើសមាហរណកម្មខ្លួនមកក្នុងសង្គមវិញ[12] ។

ចំណុចគួរកត់សម្គាល់៖ បើពិនិត្យមើលទៅលើច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ " ការងារសម្រាប់ក្មេង " បានកំណត់ត្រឹមតែអាយុ ១៥ ឆ្នាំប៉ុណ្ណោះ អាចធ្វើការងារជាកម្មករនិយោជិតបានហើយ[13]។ ដោយហេតុថា ការងារនេះគឺជាការងារមួយដែលអនីតិជនធ្វើហើយគឺអាចផ្តល់នូវផលកម្រៃតបស្នងចំពោះអនីតិជននោះវិញ ហើយកម្រៃដែលទទួលបាននេះ អាចយកទៅចិញ្ចឹមគ្រួសារ និងអនីតិជនខ្លួនឯងបានផងដែរ ។ តែដោយឡែក ផ្សារភ្ជាប់ជាមួយការងារសហគមន៍ដែលយើងកំពុងតែសិក្សានេះ គឺគ្មានកម្រៃសម្រាប់ផ្តល់ឲ្យអនីតិជននោះទេ ដូច្នេះការដែលច្បាប់បានកំណត់ត្រឹមអាយុ ១៦ ឆ្នាំនេះ គឺជាការល្អប្រសើរបំផុតណាស់ទៅហើយ ។

### ២.១.១.២. ស្ថានភាពសម្រាលទោសចំពោះអនីតិជន

កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថាន សម្រាលទោស។ ស្ថានសម្រាលទោសក៏អាចត្រូវបានផ្តល់ឲ្យជនជាប់ចោទបានដែរ ទោះបីជាជននោះ ត្រូវបានប្រកាសថាស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ[14]។ ដូច្នេះ បើពិនិត្យស្ថានសម្រាលទោសខាងលើនេះ អាចយកទៅអនុវត្តលើគ្រប់បទ ល្មើសបានទាំងអស់[15]។

ស្ថានសម្រាលទោស គឺជាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ដែលញ៉ាំងឲ្យតុលាការសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស មានន័យថា ស្ថានសម្រាលទោស គឺជា

[12] មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[13] មាត្រា ១៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧

[14] មាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[15] មាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

ការគិតគូររបស់តុលាការដោយផ្អែកទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះតម្រូវ។ ហើយការពិចារណានេះអាចតាមរយៈ សាវតា ចំណេះដឹង អាកប្បកិរិយា ស្ថានភាពគ្រួសារ ឬមួយក៏ការសារភាពទទួលស្គាល់នូវទោសកំហុសដោយខ្លួនឯង និងគ្មានការបង្ខិតបង្ខំ ណាមួយឡើយ[16]។ ដូចនេះ ក្នុងករណីដែលតុលាការបានសម្រេចឲ្យអនីតិជន បានទទួលនូវស្ថានសម្រាលទោស នោះអប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបន្ថយតាមខ្នាតដោយឡែកដូចខាងក្រោម ៖

ក. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

ខ. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ៦ (ប្រាំមួយ) ខែ ។

គ. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ៣ (បី) ខែ ។

ឃ. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ថ្ងៃ ។

ង. អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

សូមបញ្ជាក់ថា នេះគឺជាខ្នាតមួយដែលច្បាប់បានធ្វើការកម្រិត និងបញ្ញត្តិទុកសម្រាប់ឲ្យចៅក្រមយកទៅអនុវត្តលើករណីដែលអនីតិជនត្រូវទទួលបាននូវស្ថានសម្រាលទោស។ បើពិនិត្យមើលទៅ យើងឃើញថាខ្នាតនេះ គឺមានលក្ខណៈថយជាងនីតិជន ហើយការថយនេះទៀតសោធន៍ គឺរហូត ទៅដល់ស្មើនឹងពាក់កណ្តាលនៃខ្នាតដែលត្រូវយកទៅអនុវត្តសម្រាប់នីតិជនឯណោះ។ ហើយមូលហេតុដែលច្បាប់បានពង្រីកដែនអនុវត្តនូវស្ថានសម្រាលទោសទៅដល់អនីតិជនបែបនេះ អាស្រ័យដោយហេតុថា នីតិករបានពិចារណាទៅលើអនីតិភាពនៃអនីតិជននេះឯង ដោយក្នុងគោលបំណង ដើម្បីឲ្យអនីតិជនអាចទទួលបាននូវប្រយោជន៍ត្រួតគ្នា ពីការកាត់បន្ថយទោសដោយស្វ័យប្រវត្តិ និង ពីអានុភាពនៃការអនុវត្តដោយចៅក្រមនូវស្ថានសម្រាលទោសដូចទៅនឹងខ្នាតដែលបានកំរិតខាងលើ។

ឧទាហរណ៍ ៖ បទល្មើសមួយដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ បើនីតិជនប្រព្រឹត្តហើយត្រូវទទួលនូវស្ថានសម្រាលនេះគឺអាចសម្រាល មកត្រឹម ២(ពីរ) ឆ្នាំ ដែល

[16] មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

ទាបជាងគេ។ ប៉ុន្តែបើអនីតិជនប្រព្រឹត្តវិញ គឺការដែលគិតគូរនូវស្ថានសម្រាលនេះអាចថយមកនៅរហូត ១ (មួយ) ឆ្នាំ ទាបជាងគេ នេះគឺចែងសម្រាប់ដាក់ទោសទៅលើអនីតិជនដាច់ដោយឡែក។

ក្នុងចំណុចនេះ គួរកត់សម្គាល់ថា ទោះបីជាតុលាការរកឃើញថា អនីតិជននោះបានប្រព្រឹត្តបទល្មើសស្ថិត ក្នុងលក្ខខណ្ឌនៃការមិនរាងចាលក៏ដោយ ក៏តុលាការមិនអាចអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាលទៅលើអនីតិជន នោះបានទេ ពោលគឺអនីតិជននោះនៅតែត្រូវទទួលបាននូវស្ថានសម្រាលទោសដដែល ។

ជាងនេះទៅទៀត បទបញ្ញត្តិស្តីពីការមិនរាងចាល មិនត្រូវលើកយកមកអនុវត្តលើអនីតិជនឡើយ[17] មាន ន័យថាទោះបីជាអនីតិជននោះ បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមិនរាងចាលក៏ដោយ ក៏តុលាការមិនអាចយក ស្ថានទម្ងន់ទោសនេះ មកអនុវត្តលើអនីតិជននោះបានឡើយ ។

**២.១.២. វិធានការបង្វែរ**

ការបង្វែរ ជាវិធានការដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើសហើយ ដែលអាចជឿជាក់បានថា បានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ[18]។ មាន ន័យថា ការបង្វែរនេះគឺជាវិធានការមួយដែលតម្រូវឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ហើយមានរយៈពេលកំណត់ ណាមួយជាក់លាក់។ អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃ សាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍[19] ។

**២.១.២.១. លក្ខខណ្ឌនៃការបង្វែរ**

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរ អាចសម្រេចជ្រើសរើសយកនូវវិធានការ មួយ ឬច្រើន សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច។ ប៉ុន្តែមុននឹងឈានទៅដល់ការរៀបចំបង្កើត នូវផែនការបង្វែរទៅបាន ចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌអប្បបរមានៃការបង្វែរ និងពិចារណាអំពីលក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរជាមុនសិន ។ លក្ខខណ្ឌអប្បបរមានៃការបង្វែរ[20] រួមមាន៖

. មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន។ អនីតិជនសារភាពទទួល កំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ។

. បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម។

---

[17] មាត្រា១៦៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[18] មាត្រា៦០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[19] មាត្រា៦១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[20] មាត្រា៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

. អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារ សង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរ អំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ ។

លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ[21] ត្រូវពិចារណាទៅលើកត្តាមួយចំនួនរួមមាន ៖

. កាលៈទេសៈនៃបទល្មើស។

. ស្ថានភាពនៃបទល្មើស។

. បុគ្គលិកលក្ខណៈរបស់នីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត។

. ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន

. ព្យសនកម្មរបស់ជនរងគ្រោះ និង

. សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គមផងដែរ ។

ក្រោយពីបានបំពេញនូវលក្ខខណ្ឌអប្បបរមា និង លក្ខណៈវិនិច្ឆ័យសម្រាប់ការបង្វែររួចហើយ អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវជ្រើសរើសយកនូវវិធានការមួយ ឬច្រើនទុកសម្រាប់ឲ្យអនីតិជនបំពេញ ជាកាតព្វកិច្ចមុននឹងចេញដីកាសម្រេចបង្វែរទៅឲ្យភ្នាក់ងារសង្គមកិច្ច ដើម្បីរៀបចំអនុវត្តនូវផែនការបង្វែរឡើង ដោយវិធានការនោះ[22] រួមមាន៖

. ចំណុចមួយ ឬ ច្រើនដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការ ត្រួតពិនិត្យតាមផ្លូវតុលាការ

. ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ

. ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ

. តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងចិរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ

. ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំឡើងទៅ ហើយមានលក្ខណៈ ជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញតែប៉ុណ្ណោះ

. អនីតិជនមិនចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយឲ្យអនីតិជនប្រព្រឹត្តបទល្មើសសារជាថ្មី

. ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់

[21] មាត្រា៦៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] មាត្រា៦៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

. ជួសជុលសំណង់ ការខូចខាតទៅជនរងគ្រោះ និងអាចមាន

. វិធានការសមស្របផ្សេងៗទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

គួរកត់សម្គាល់ផងដែរថា រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុទ្បោមតាមច្បាប់ ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់។

**២.១.២.២. ការអនុវត្តនូវផែនការបង្វែរ**

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានារ៉ាប់រងអនុវត្តសេចក្តី សម្រេច និង ផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្ត ផែនការបង្វែរ[23] ។ បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលជោគជ័យឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តលើផែនការទៅលើភ្នាក់ងារសង្គមកិច្ច។ ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូន របាយការណ៍ រួមទាំងយោបល់របស់ខ្លួនទៅ អាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យ សង្គមកិច្ចរាជធានី ខេត្ត។ ក្រោយពីបានទទួលនូវដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គម កិច្ចត្រូវ រៀបចំបង្កើតនូវផែនការបង្វែរនោះឡើង។ ជាមួយគ្នានេះដែរ ក្នុងការរៀបចំបង្កើតនូវផែនការបង្វែរ ភ្នាក់ងារ សង្គមកិច្ចត្រូវសម្រេចនៅក្នុងកំឡុងពេលមិនឲ្យលើសពី ១ (មួយ) ខែឡើយ ដោយគិតចាប់ ពីថ្ងៃទទួលដំណឹង សម្រេចអំពីការបង្វែរនេះ។ មួយវិញទៀត ក្នុងកំឡុងពេលនៃការសម្រេចនេះផងដែរ ភ្នាក់ងារសង្គមកិច្ចក៏ត្រូវ ពិចារណាទៅលើកត្តាមួយចំនួនទៀតរួមមាន[24] ៖

. ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់ នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង

. សាវតា វប្បធម៌ សាសនា និងភាសារបស់អនីតិជន

. កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន

. សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន បទល្មើស និងផល ប្រយោជន៍សង្គម ក្រៅពីនេះក៏ត្រូវពិចារណាទៅលើ

. អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជនផងដែរ។

បន្ទាប់ពីភ្នាក់ងារសង្គមកិច្ចសម្រេចអំពីផែនការបង្វែររួចរាល់ហើយ ភ្នាក់ងារនេះត្រូវបញ្ជូន ផែនការបង្វែរ ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីធ្វើការពិនិត្យ និងសម្រេចតាមការគួរ។ ក្នុងករណី អាជ្ញាធរទទួលបន្ទុកបង្វែរ យល់ស្របចំពោះផែនការបង្វែរនេះ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញនូវ ដីកាសម្រេចដើម្បីដាក់ឲ្យអនុវត្តនូវ

[23] មាត្រា៦៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[24] មាត្រា៦៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ផែនការបង្វែរនោះភ្លាម។ ប៉ុន្តែដោយឡែក ក្នុងករណីអាជ្ញាធរភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំឡើងវិញនូវផែនការបង្វែរថ្មីមួយទៀត។ ហើយផែនការបង្វែរថ្មីនេះត្រូវសម្រេចក្នុងកំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់នោះ ។

## ២.២. លំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន

នីតិវិធីដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន ក៏មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីអនុវត្តចំពោះនីតិជនផងដែរ។ ដោយហេតុថា ក្នុងការអនុវត្តនីតិវិធីនេះ តម្រូវឱ្យមានការឆ្លងកាត់ពីដំណាក់កាលនីមួយៗ ក្នុងនោះរួមមានការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ចំណាត់ការសំណុំរឿងដោយស្ថាប័នអយ្យការ ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះធ្វើឡើងនៅក្នុងសវនាការជាអាទិ៍។ ក៏ប៉ុន្តែអ្វីដែលខុសគ្នានោះ ត្រង់ថាអនីតិជនជាជនដែលមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិតនៅឡើយ។ ដូច្នេះ ត្រង់ចំណុចនេះហើយទើបច្បាប់បានពិចារណាទៅលើកម្រិតនៃការយល់ដឹងរបស់ពួកគេ តម្រូវឲ្យមាននូវការអនុវត្តនីតិវិធីយ៉ាងពិសេសមួយចំនួនចំពោះអនីតិជន។

### ២.២.១. នីតិវិធីនៃការស៊ើបអង្កេត និងចំណាត់ការសំណុំរឿង

ជាទូទៅ រឿងក្តីព្រហ្មទណ្ឌចាប់ផ្តើមឡើងដោយមានការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចស្វែងរកឃើញថា អង្គហេតុមួយចំនួនត្រូវបានចាត់ទុកថាជាបទល្មើស។ ការស៊ើបអង្កេតគឺជាដំណាក់កាលត្រៀមនៃរឿងក្តីព្រហ្មទណ្ឌ ដែលប្រព្រឹត្តទៅមុនពេលការចាប់ផ្តើមចោទប្រកាន់ក្នុងបំណងស្វែងរកនៅភស្តុតាង[25]។ ក្រោយពីបានបញ្ចប់នូវការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនសំណុំរឿងទៅកាន់ស្ថាប័នអយ្យការដើម្បីមានចំណាត់ការបន្ត។ សំណុំរឿងនៃនីតិវិធីដែលបានកសាងឡើងដោយការស៊ើបអង្កេតយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ព្រះរាជអាជ្ញាដែលមានតួនាទីបន្ទាប់ត្រូវសម្រេចថានឹងមានចំណាត់ការយ៉ាងណាបន្តទៀត ដោយយោងទៅលើភាពជាក់ស្តែងនិងស្ថានភាពភស្តុតាងដែលប្រមូលបាន។[26]

#### ២.២.១.១. ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចស៊ើបអង្កេតលើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដែលពាក់ព័ន្ធទៅនឹងជនសង្ស័យដែលជាអនីតិជន[27]។ រាល់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងក្រោមការដឹកនាំនិងសម្របសម្រួលសកម្មភាពពីព្រះរាជអាជ្ញា[28]។ នៅក្នុងដំណើរការស៊ើបអង្កេតនេះ មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីកំណត់ពីប្រភេទនៃបទល្មើស អត្តសញ្ញាណ ប្រមូលភស្តុតាង ដែលពាក់ព័ន្ធដើម្បីឃាត់ខ្លួន និងចាប់ខ្លួន

[25] មេរៀននីតិវិធីព្រហ្មទណ្ឌ,រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឆ្នាំ២០០៨ ទំព័រ ៩

[26] មេរៀននីតិវិធីព្រហ្មទណ្ឌ,រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឆ្នាំ២០០៨ ទំព័រ ២៩

[27] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១២ ឆ្នាំ២០១៦

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ,មាត្រា ៥៨ ឆ្នាំ២០០៧

ជនល្មើសក្នុងករណីដែលចាំបាច់។ ទន្ទឹមនឹងនេះ ក្នុងករណីនៃការស៊ើបសួរអង្កេតទាក់ទងទៅនឹងអនីតិជន ការស៊ើបអង្កេតត្រូវបានធ្វើឡើងដោយមន្ត្រីជំនាញ ដែលបានទទួលការបណ្តុះបណ្តាលពីច្បាប់ទាំងឡាយ ដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ ដោយក្នុងគោលដៅ ដើម្បីអាចឲ្យការអនុវត្តនោះប្រព្រឹត្តទៅដោយលក្ខណៈ នីតិវិធីកុមារមេត្រី។ ដូចនេះ ការស៊ើបអង្កេតនេះត្រូវបង្ហាញ និងប្រព្រឹត្តទៅតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

**ការចាប់ខ្លួន**

បន្ទាប់ពីរកឃើញថាអនីតិជនបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាបានប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការឃាត់ខ្លួនអនីតិជននោះ នឹងរាយការណ៍ទៅព្រះរាជអាជ្ញាភ្លាម ដើម្បីធ្វើការចាប់ខ្លួនអនីតិជនដែលជាប់សង្ស័យនោះ។

លក្ខណៈពិសេសនៃការចាប់ខ្លួន គឺមន្ត្រីនគរបាលអាចធ្វើការចាប់ខ្លួនបានចំពោះតែអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងតែប៉ុណ្ណោះ[29]។ ក្នុងការអនុវត្តន៍ការចាប់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ត្រូវជៀសវាងជាដាច់ខាត ក្នុងការធ្វើឱ្យអាម៉ាស់មុខ នឹងបាត់បង់សេចក្តីថ្លៃថ្នូរដល់អនីតិជន។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រើប្រាស់កម្លាំងក្នុងកម្រិតស្រាលបំផុតតាមដែលអាចធ្វើទៅបាន ដោយជៀសវាងការប្រើប្រាស់នូវឧបករណ៍មួយចំនួនដែលមានលក្ខណៈបង្ខំ ដូចជាខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែល ហើយត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពនគរបាលយុត្តិធម៌ជំនាញទាក់ទងទៅនឹងអនីតិជនដែលនៅជិតបំផុត។ មួយវិញទៀត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរទៅលើខ្លួនបុគ្គលដែលជាអនីតិជនដែលមានភេទដូចគ្នាប៉ុណ្ណោះ ក្នុងករណីដែលគ្មានជម្រើសមន្ត្រីនគរបាលយុត្តិធម៌ អាចអនុញ្ញាត និងធ្វើការចាត់តាំងនីតិជនដែលមានភេទដូចគ្នាណាម្នាក់ឲ្យធ្វើការឆែកឆេរទៅលើអនីតិជនដែលមានភេទដូចគ្នា តែត្រូវប្រាកដថាអ្នកដែលធ្វើការឆែកឆេរនោះមិនមានជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ (លើកលែងតែក្នុងករណីដែលមិនអាចជៀសវាងបាន)[30] ។

បន្ទាប់ពីធ្វើការចាប់ខ្លួនអនីតិជនភ្លាម មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់នូវសិទ្ធិមួយចំនួនទៅកាន់អនីតិជនដូចជា[31] ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលមាន ឬគ្មានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំអោយឆ្លើយដាក់បន្ទុកលើខ្លួនឯង

[29] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៥ ឆ្នាំ២០១៦

[30] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៦ ឆ្នាំ២០១៦

[31] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៦ ឆ្នាំ២០១៦

- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកតម្លៃស្របតាមលក្ខខណ្ឌ ដូចដែលមានចែងនៅក្នុងច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលនៃនីតិវិធី
- សិទ្ធិអោយមានការចូលរួមពីអ្នកដំណាងដែលច្បាប់កំណត់ នៅគ្រប់ដំណាក់កាលនៃរឿងក្តី ប្រសិនបើការចូលរួម នេះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំអោយកោះហៅសាក្សី ឬសាកសួរសាក្សី
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស និងសិទ្ធិផ្សេងៗទៀតដូចមាន ចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។

**ការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឃាត់ខ្លួនអនីតិជនបាន ប្រសិនបើជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន និង បន្តផលប៉ះពាល់ទៅដល់ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ។ ដោយឡែក ករណីអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ ១៦ (ដប់ប្រាំមួយ)ឆ្នាំ ការឃាត់ខ្លួនអាច ធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈឹមដោយចេតនាប៉ុណ្ណោះ ហើយរាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម (ការឃាត់ខ្លួន គឺសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ)[32] ។

ប្រសិនបើនីតិវិធីឃាត់ខ្លួនត្រូវបានអនុវត្ត លក្ខណៈពិសេសនៃការអនុវត្តការឃាត់ខ្លួនលើអនីតិជននោះ គឺ មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពី អនីតិជន ចាំបាច់ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី និងអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុក បម្រុងរបស់អនីតិជននោះជាមុន[33]។ ប្រសិនបើអនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃពីសំណាក់អនីតិជននោះផងដែរ។ នីតិវិធីមួយទៀត ដែលចាំបាច់បំផុតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវធានាថាអនីតិជនដែលត្រូវបានឃាត់ខ្លួន មិនត្រូវបានទទួលទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុត បំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀត ដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬ ទទួលរងអំពើ

[32] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៧ ឆ្នាំ២០១៦
[33] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៣ ឆ្នាំ២០១៦

អមនុស្សធម៌ណាមួយឡើយ ដែលស្របទៅនឹងគោលការណ៍ក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងលិខិតតុបករណ៍នានា។

មន្ត្រីនគរបាលយុត្តិធម៌ ចាំបាច់ត្រូវតែបញ្ចប់ដំណើរការស៊ើបអង្កេតរបស់ខ្លួនឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបានសម្រាប់ជាឧត្តមប្រយោជន៍របស់អនីតិជន។ ចំពោះរយៈពេលនៃការឃាត់ខ្លួនវិញ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនត្រឹមរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ប៉ុណ្ណោះ ប្រសិនបើគ្មានតម្រុយពីបទល្មើសដែលអនីតិជននោះបានប្រព្រឹត្តទេនោះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចបន្តរយៈពេលឃាត់ខ្លួនបានទៀតនោះទេ គឺត្រូវធ្វើការដោះលែងអនីតិជននោះឲ្យត្រឡប់ទៅវិញ ដោយមានការធានាពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន។

ជាគោលការណ៍ អនីតិជនដែលត្រូវបានឃាត់ខ្លួន ត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទរបស់អនីតិជននោះ។ ប៉ុន្តែសូមបញ្ជាក់ផងដែរថា ក្នុងស្ថានភាពបច្ចុប្បន្ននេះនៅមិនទាន់អាចអនុវត្តបានទាំងស្រុងនៅឡើយទេ អាស្រ័យដោយហេតុថា នៅមានកង្វះខាតធនធានមនុស្ស កត្តាសម្ភារៈ និងយន្តការច្បាស់លាស់ទើបធ្វើឲ្យការអនុវត្តជាក់ស្តែងមិនទាន់ប្រព្រឹត្តបានត្រឹមត្រូវនូវឡើយ។ ដោយយើងសង្កេតឃើញថា អនីតិជនត្រូវបានដាក់លាយឡំជាមួយនឹងនីតិជនដែលត្រូវបានឃាត់ខ្លួន ហើយរាជរដ្ឋាភិបាលក៏កំពុងនឹងផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហានេះផងដែរ ដោយបានអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះឡើងក្នុងគោលបំណងផ្តល់ការយកចិត្តដាក់ខ្ពស់ទៅលើករណីនេះ។

**ការស្តាប់ចម្លើយ**[34]

ការស្តាប់ចម្លើយអនីតិជន ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌព្រមទាំងវិធានមួយចំនួនទៀតដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ មេធាវី និងសេវាសង្គមកិច្ច ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន នៅពេលអនីតិជននោះ ត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាលយុត្តិធម៌។ ក្រោយពេលអនីតិជនត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាលយុត្តិធម៌រួចមកមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការជូនដំណឹងភ្លាមទៅកាន់ភ្នាក់ងារសេដ្ឋកិច្ច និងមេធាវីរបស់អនីតិជនផ្ទាល់។

ក្នុងករណីដែលអនីតិជន មិនមានមេធាវី មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដែលត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស។ ចំពោះអនីតិជន ដែលជាជនបរទេស ឬជនជាតិភាគតិច មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្វែងរក ផ្តល់អ្នកបកប្រែភាសា ដោយមិនយកកម្រៃពីអនីតិជនឡើយ ប្រសិនបើអនីតិជននោះពុំមានអ្នកបកប្រែផ្ទាល់ខ្លួន។

[34] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៣ ឆ្នាំ២០១៦

បន្ទាប់ពីបានបំពេញលក្ខខណ្ឌទាំងនេះរួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុសរុបស្ដីពីការចាប់ខ្លួន និងការឃាត់ខ្លួនអនីតិជន (ប្រសិនបើមាន)។ កំណត់ហេតុនេះអាចផ្ដល់ឲ្យមេធាវីផងដែរ ប្រសិនបើមានការស្នើសុំ ប៉ុន្តែក្នុងទ្រង់ទ្រាយជាច្បាប់ចម្លងតែប៉ុណ្ណោះ។

មុនពេលចាប់ផ្ដើមស្ដាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋាន និងសិទ្ធិមិនផ្ដល់ចម្លើយនៅពេលមាន ឬគ្មានវត្តមានមេធាវី ដូចទៅនឹងនីតិវិធីអនុវត្តចំពោះបុគ្គលដែលជានីតិជនដែរ។ ការស្ដាប់ចម្លើយអនីតិជន គឺត្រូវធ្វើឡើងជាលក្ខណៈឯកជន និងជាការសម្ងាត់ ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី និងចាំបាច់ត្រូវមានវត្តមានរបស់មេធាវី។ ចំណែកឯអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច មានសិទ្ធិផ្ដល់ជំនួយដល់អនីតិជន និងចូលរួមក្នុងការស្ដាប់ចម្លើយអនីតិជននោះបានផងដែរ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌អាចបដិសេធពីការចូលរួមរបស់អ្នកទាំងនោះបាន ប្រសិនបើយល់ឃើញថាវត្តមានរបស់អ្នកទាំងនោះ អាចធ្វើឱ្យខូចដល់ឧត្ដមប្រយោជន៍របស់អនីតិជន។ ការបដិសេធ គឺត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជនផ្ទាល់។

បន្ទាប់ពីបញ្ចប់ការស្ដាប់ចម្លើយភ្លាម អនីតិជន និងបុគ្គលដែលបានរៀបរាប់ខាងលើអាចអាន និងធ្វើការពិនិត្យកំណត់ហេតុស្ដាប់ចម្លើយបាន។ អនីតិជន ក៏អាចធ្វើការសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្ដាប់ចម្លើយនោះផងដែរ មុននឹងចុះហត្ថលេខា និងផ្ដិតម្រាមដៃ។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា និងផ្ដិតម្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្ដិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនោះ។

បន្ទាប់ពីបានធ្វើកំណត់ហេតុ និងពិនិត្យផ្ទៀងផ្ទាត់ដោយអនីតិជនរួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ជំនាញបញ្ចប់នីតិវិធីរបស់ខ្លួន រួចបញ្ជូនសំណុំរឿងបន្តទៅកាន់តំណាងអយ្យការដើម្បីពិនិត្យ និងមានចំណាត់ការបន្ត។

#### ២.២.១.២. ចំណាត់ការសំណុំរឿងដោយអយ្យការ

ក្រោយពីបានទទួលសំណុំរឿងបន្តពីមន្ត្រីនគរបាលយុត្តិធម៌ហើយ តំណាងអយ្យការធ្វើការអនុវត្តបណ្ដឹងអាជ្ញា ដោយត្រួតពិនិត្យទៅលើសំណុំរឿង នឹងធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ ដែលទាក់ទងទៅនឹងអនីតិជន[35]។ ក្នុងករណីដែលមានការសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកអោយឃើញអាយុពិតប្រាកដរបស់អនីតិជននោះ[36]។ នីតិវិធីរបស់ព្រះរាជអាជ្ញា

[35] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា ២៤ ឆ្នាំ២០១៦

[36] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា ២៥ ឆ្នាំ២០១៦

ក៏មិនមានលក្ខណៈអ្វីខុសប្លែកពីនីតិវិធីរបស់នគរបាលយុត្តិធម៌នោះទេ ដោយព្រះរាជអាជ្ញាធ្វើការស្តាប់ចម្លើយរបស់អនីតិជន និងធ្វើការសន្និដ្ឋានទៅលើសំណុំរឿងនោះ ដោយអនុវត្តតាមគោលការណ៍កាលានុវត្តភាព។

**គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ចំពោះអនីតិជន**[37]

ក្រោយពីបានថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងហើយ ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់ទៅលើអនីតិជនបាន។ ព្រះរាជអាជ្ញា អាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរបន្ថែមទៅលើអនីតិជនដែលជាជនជាប់ចោទនោះ។ បន្ទាប់ពីធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងពីបទចោទប្រកាន់នោះទៅអនីតិជនដែលជាជនជាប់ចោទភ្លាម និងឪពុកម្តាយ ឬអាណាព្យាបាល និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន[38] ។

ក្នុងករណីដែលមានការបារម្ភថា អនីតិជនអាចនឹងរត់គេចខ្លួន ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការឃុំខ្លួនអនីតិជននោះបាន (ការស្នើសុំនេះសម្រាប់តែមធ្យោបាយចុងក្រោយបង្អស់តែប៉ុណ្ណោះ)។ ជាមួយគ្នានេះ ព្រះរាជអាជ្ញាក៏ត្រូវពិចារណាដល់វិធានការផ្សេងទៀត ដែលមានលក្ខណៈប្រសើរដូចជា វិធាននៃការបង្វែរជាដើម ដែលបម្រើដល់ឧត្តមប្រយោជន៍របស់អនីតិជននោះផងដែរ។

ស្របតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ព្រះរាជអាជ្ញាត្រូវយកវិធានការបង្វែរនេះមកអនុវត្តជាមុនសិន មុននឹងសម្រេចធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការឃាត់ខ្លួនអនីតិជននោះ។ វិធានការនេះអាចអនុវត្តបានចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទលហុ និងបទមជ្ឈិម[39]។

**២.២.២. នីតិវិធីនៃការស៊ើបសួរ និងការជំនុំជម្រះ**

ការស៊ើបសួរ គឺជាដំណាក់កាលដែលចៅក្រមស៊ើបសួរប្រមូលផ្តុំនូវធាតុផ្សំចាំបាច់សម្រាប់ការកាត់សេចក្តី និងសម្រេចថានឹងធ្វើដូចម្តេចចំពោះការចោទប្រកាន់[40]។ ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់[41]។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ក្រោយពីបានបិទបញ្ចប់នូវកិច្ចស៊ើបសួរហើយ ចៅក្រម

[37] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៩ ឆ្នាំ២០១៦

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ,មាត្រា ៤០ ឆ្នាំ២០០៧

[39] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៨ ឆ្នាំ២០១៦

[40] មេរៀននីតិវិធីព្រហ្មទណ្ឌ,រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៨ ទំព័រ ៤០

[41] យោងតាមមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៩

ស៊ើបសួរត្រូវបញ្ជូនសំណុំរឿងនោះទៅចៅក្រមជំនុំជម្រះ ដើម្បីធ្វើការជំនុំជម្រះដោយហេតុថាមានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី[42]។

### ២.២.២.១. ការស៊ើបសួរធ្វើឡើងវិញដោយចៅក្រមស៊ើបសួរ

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបអង្កេតភ្លាម និងត្រូវលើកយករឿងក្តីរបស់អនីតិជនយកមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន[43]។ ការស៊ើបសួរ ករណីនៃទាំងឡាយណាដែលពាក់ព័ន្ធទៅនិងអនីតិជន ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ដែលមានជំនាញទាក់ទងទៅនឹងអនីតិជន។ នៅពេលអនីតិជនបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីសិទ្ធិទាក់ទងទៅនឹងតំណាក់កាលនៃការស៊ើបសួរ។

ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីជានិច្ចក្នុងកំឡុងពេលស្តាប់ចម្លើយ និងនៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្នុងករណីគ្មានការជ្រើសរើសចៅក្រមស៊ើបសួរ ត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[44]។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យនេះ។

ចំពោះការស្តាប់ចម្លើយអនីតិជន[45] ត្រូវធ្វើជាសម្ងាត់ ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី និងត្រូវមានវត្តមានមេធាវីការពារ ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬទំនុកបម្រុងរបស់អនីតិជនផងដែរ។ ចៅក្រមស៊ើបសួរ អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងអស់នោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។ ការមិនអនុញ្ញាតិនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។

បន្ទាប់ពីបានបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយ ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ។ ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន។ មេធាវីអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង

[42] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ មាត្រា១២៩ ថ្មី (មាត្រា ១១០ ចាស់) កថាខណ្ឌ២ វាក្យខណ្ឌ១

[43] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៨ ឆ្នាំ២០១៦

[44] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣២ ឆ្នាំ២០១៦

[45] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៥ ឆ្នាំ២០១៦

របស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃនៅលើកំណត់ហេតុ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយបាន។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏បានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងការអនុវត្តនូវវិធានការបង្វែរនេះផងដែរ។ ក្នុងករណីដែលអនីតិជនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈឹម ឬបទមជ្ឈឹមដែលមានស្ថានទម្ងន់ទោស ចៅក្រមស៊ើបសួរត្រូវធ្វើការពិចារណាជាបឋមទៅលើការបង្វែរ មុននឹងទៅប្រើនូវវិធានការផ្សេងពីនេះ (ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន)។

ជាគោលការណ៍ ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្នត្រូវតែជាវិធានការចុងក្រោយបំផុត។ ប៉ុន្តែការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្ននេះ ក៏អាចធ្វើឡើងបានផងដែរនៅក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា អនីតិជនទំនាស់នឹងច្បាប់អាចបង្កភាពចលាចលនៅកំឡុងពេលស៊ើបអង្កេត។ បន្ថែមលើបទបញ្ញត្តិស្តីពីលក្ខខណ្ឌ ហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ(ប្រសិនបើមាន)[46]។

ចៅក្រមស៊ើបសួរ អាចដាក់អនីតិជនជាជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ជំនួសឲ្យការឃុំខ្លួនជាបណ្តោះអាសន្ន ប្រសិនបើ អនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ បន្ថែមលើបទបញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពតាមកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ[47]។

ដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្របឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជនបង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង ឬវិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប។

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាទៅលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អតិថិជន។ ក្នុងករណីរបាយការណ៍ស្តីពីការប៉ាន់

[46] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៩ ឆ្នាំ២០១៦

[47] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤០ ឆ្នាំ២០១៦

ប្រមាណសុខមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។

បន្ទាប់ពីចៅក្រមស៊ើបសួរ បានចេញសេចក្តីសម្រេចរបស់ខ្លួនរួចមក ព្រះរាជអាជ្ញាអាចធ្វើការប្តឹងទៅសភាស៊ើបសួរនៅសាលាឧទ្ធរណ៍បានចំពោះដីកាដែលសម្រេចដោយចៅក្រមស៊ើបសួរ ក្នុងករណីដែលយល់ឃើញថា សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរមិនសមស្រប ដោយពិចារណាជាចម្បងពីឧត្តមប្រយោជន៍របស់អនីតិជននោះ។

### ២.២.២.២. ការជំនុំជម្រះ

កាលបើសំណុំរឿងត្រូវបានកសាងរួចហើយ រឿងក្តីអាចត្រូវបានបញ្ចប់ លុះត្រាតែបានឆ្លងកាត់នូវការជំនុំជម្រះដែលធ្វើឡើងនៅក្នុងសវនាការ និងរួមទាំងប្រកាសសាលក្រមផងដែរ។ ការជំនុំជម្រះលើរឿងក្តីអនីតិជន ត្រូវធ្វើឡើងដោយចៅក្រមជំនុំជម្រះដែលមានជំនាញទាក់ទងទៅនឹងអនីតិជនដែលមានសមាសភាពចៅក្រមជំនុំជម្រះចំនួន ៣ (បី) រូបធ្វើការពិភាក្សា និងសម្រេចថាអនីតិជនមាន ឬគ្មានបទល្មើស[48]។

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ [49] ។ មានតែបុគ្គលដែលមានសិទ្ធិ និងកាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីតែប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសាវនាការបាន។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឱ្យឧត្តមប្រយោជន៍របស់អនីតិជន។

នៅពេលសវនាការ តុលាការប្រើនីតិវិធីកុមារមេត្រី [50] ។ ក្នុងកាលៈទេសៈពិសេសមេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។ ជាមួយគ្នានេះ ជំនួយរបស់មេធាវី ត្រូវតែមានជាដាច់ខាតក្នុងពេលសវនាការ។ ក្នុងករណីដែលគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃ តាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

នៅពេលផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានអំពីសិទ្ធិមួយចំនួនដូចខាងក្រោម[51] ៖

[48] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៥ ឆ្នាំ២០១៦
[49] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៧ ឆ្នាំ២០១៦
[50] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៨ ឆ្នាំ២០១៦
[51] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៥១ ឆ្នាំ២០១៦

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្តឹងឧទ្ធរណ៍ ជាអាទិ៍។

វិធានការបង្វែរ ក៏ត្រូវបានលើកយកមកពិចារណាក្នុងដំណាក់កាលនៃការជំនុំជម្រះដូចទៅនឹងដំណាក់ការព្រះរាជអាជ្ញា និងដំណាក់កាលចៅក្រមស៊ើបសួរផងដែរ។ ដោយចៅក្រមជំនុំជម្រះមានអំណាចក្នុងការអនុវត្តវិធានការបង្វែរ ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ដែលជាប់ចោទពីបទលហុ បទមជ្ឈិម និងបទមជ្ឈិមមានស្ថានទម្ងន់ទោស។ ចៅក្រមត្រួតពិនិត្យ និងពិចារណាលើលក្ខខណ្ឌអប្បបរមាដែលតម្រូវឲ្យបំពេញដោយអនីតិជន ដើម្បីអាចអនុវត្តវិធានការនេះបាន។ មួយវិញទៀត ប្រសិនបើអនីតិជនបានសារភាពនៅកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តក្នុងពេលជំនុំជម្រះ តុលាការត្រូវត្រួតពិនិត្យថ្លឹងថ្លែង និងបញ្ជាក់ថា ចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តនឹងគ្មានការគំរាមកំហែង ឬការបង្ខិតបង្ខំណាមួយឡើយ។ រាល់ចម្លើយសារភាពរបស់អនីតិជនដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ មិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ ចំពោះការសារភាពទទួលយកផែនការបង្វែរ មិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែលសម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ។ ក្នុងពេលសវនាការ តុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។

សាលក្រមអាចត្រូវបានប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ ជាគោលកាណ៍ សាលក្រមត្រូវបានប្រកាសឡើងជាសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ឬភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។

# ជំពូកទី៣
# ការអនុវត្តទោសចំពោះ
# អនីតិជន

# ជំពូកទី៣

# ការអនុវត្តទោសព្រហ្មទណ្ឌចំពោះអនីតិជន

## ៣.១. ការអនុវត្តទោសចំពោះអនីតិជន

ការអនុវត្តទោស គឺជាដំណើរការនៃការអនុវត្តតាមនីតិវិធីដែលតុលាការបានធ្វើការផ្តន្ទាទោសចំពោះជនល្មើស ពោលគឺក្រោយពីតុលាការធ្វើការប្រកាសទណ្ឌកម្មចំពោះទណ្ឌិតណាម្នាក់រួចហើយ។ យោងតាមស្មារតីនៃច្បាប់ស្តីពីធម៌អនីតិជន រាល់ការអនុវត្តចំពោះអនីតិជន គឺធ្វើឡើងក្នុងគោលបំណងដើម្បីស្តានីតិសម្បទាដល់អនីតិជននោះតែប៉ុណ្ណោះ ហើយអនីតិជនមិនអាចត្រូវបានធ្វើការឃុំខ្លួន ឬអនុវត្តទោសដូចទៅនឹងនីតិជនឡើយ។ រាល់ការឃុំអនីតិជន ធ្វើឡើងក្នុងគោលបំណងស្តានីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឲ្យអនីតិជនក្លាយទៅជាពលរដ្ឋសុច្ចរិត និងមានប្រយោជន៍ដល់សង្គមជាតិ[52]។ ដោយឡែក ថ្វីត្បិតតែច្បាប់នេះ បញ្ញត្តិមកមានគោលបំណងបែបនេះក៏ពិតមែន ប៉ុន្តែបើក្នុងការអនុវត្តជាក់ស្តែង គេពុំទាន់ឃើញមាននូវមជ្ឈមណ្ឌលឃុំនីតិសម្បទាសម្រាប់អនុវត្តទៅចំពោះអនីតិជននៅឡើយ។ ជាមួយគ្នានេះដែរ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដដែលនេះ ក៏បានបញ្ញត្តិផ្តល់សិទ្ធដល់តុលាការ ក្នុងការប្រកាសទោសចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសក្នុងស្ថានភាពបែបនេះផងដែរ គឺក្នុងករណីមិនទាន់មានមណ្ឌលឃុំនីតិសម្បទា វិធានការទាំង ឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលឃុំនីតិសម្បទា[53]។ ដូច្នេះការអនុវត្តចំពោះអនីតិជនក្នុងស្ថានភាពបច្ចុប្បន្ន នឹងប្រព្រឹត្តទៅមានលក្ខណៈដូចខាងក្រោម៖

### ៣.១.១. ការអនុវត្តទោសដាក់ពន្ធនាគារ

ពន្ធនាគារ សំដៅដល់កន្លែងសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការរួមមានមជ្ឈមណ្ឌលឃុំខ្លួន និងមជ្ឈមណ្ឌលអប់រំកែប្រែជង[54]។ ការដាក់ពន្ធនាគារអនីតិជន ដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌត្រូវតែជាវិធានការចុងក្រោយបង្អស់ ដែលត្រូវបានប្រើតែក្នុងករណីពិសេសតែប៉ុណ្ណោះ[55]។ គោលបំណងចម្បងក្នុងការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារ គឺដើម្បីធ្វើការអប់រំ កែប្រែបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទា ដល់ទណ្ឌិតដែលជាអនីតិជននោះតែប៉ុណ្ណោះ។ ក្នុងគោលដៅ ដើម្បីក្រោយពីការអនុវត្តទោសត្រូវបានបញ្ចប់រួចហើយ អាចឲ្យអនីតិជននោះចូលមករួមរស់នៅក្នុងសង្គមដូចដើមវិញ។

---

[52] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៧៩ ឆ្នាំ២០១៦

[53] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៨៨ កថាខណ្ឌទី១

[54] ច្បាប់ស្តីពីពន្ធនាគារ,មាត្រា ៤ ចំណុច ១ ឆ្នាំ ២០១១

[55] អនុសញ្ញាស្តីពីសិទ្ធិកុមារ,មាត្រា ៣៧

**ការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ**

ការឃុំឃាំងក្នុងពន្ធនាគារ គឺជានីតិវិធីមួយដែលធ្វើការឃុំអនីតិជនដែលជាជនជាប់ឃុំនៅក្នុងបន្ទប់ឃុំឃាំង ហើយការដែលឃុំឃាំងនេះទៀតសោធន៍ ក៏ត្រូវបានបែងចែកទៅតាមប្រភេទនៃជនជាប់ឃុំនីមួយៗនោះផងដែរ។ ជនជាប់ឃុំ សំដៅដល់ជនត្រូវចោទ ឬពិរុទ្ធជន ឬទណ្ឌិត ដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ[56]។ ជនជាប់ឃុំជាអនីតិជន ត្រូវដាក់បំបែកពីជនជាប់ឃុំជានីតិជន។ ជនជាប់ឃុំ ដែលជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជន ត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត[57]។ ក្រៅពីនេះ ជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកពីជនជាប់ឃុំជាបុរស និងចំពោះជនជាប់ឃុំដែលមានជំងឺឆ្លងវិញ ក៏ត្រូវដាក់បំបែកដាច់ដោយឡែក ពីជនជាប់ឃុំដទៃទៀតផងដែរ។

ដូច្នេះ ជាបន្ទាប់មកទៀតនេះ យើងនឹងធ្វើការសិក្សាបន្តអំពីប្រភេទនៃជនជាប់ចោទក្នុងពន្ធនាគារដែលត្រូវអនុវត្តក្នុងស្ថានភាពបច្ចុប្បន្នជាបន្តះ

**ជនត្រូវចោទ** គឺជាបុគ្គលដែលត្រូវបានចោទប្រកាន់តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទៅកាន់ចៅក្រមស៊ើបសួ[58]។ ការឃុំឃាំងជាបណ្ដោះអាសន្នទៅលើអនីតិជនដែលត្រូវជនជាប់ចោទអាចធ្វើទៅបានតែក្នុងលក្ខខណ្ឌដូចដែលមានចែងកំណត់ក្នុងច្បាប់[59]។ ហើយដើម្បីអាចអនុវត្តការឃុំខ្លួនទៅលើអនីតិជននេះបាន ទាល់តែក្នុងករណីដែលអនីតិជននោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់តម្រូវអោយធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារតែប៉ុណ្ណោះ[60]។ ចំពោះរយៈពេលនៃការឃុំខ្លួនវិញ គឺមិនត្រូវឲ្យលើសពីរយៈពេលដូចដែលបានកំណត់នៅក្នុងក្រមនីតិព្រហ្មទណ្ឌទេ ព្រោះនេះជាការកំណត់របស់ច្បាប់។

**ជនជាប់ចោទ** ជាជនដែលត្រូវបានបញ្ជូនខ្លួនទៅចំពោះមុខតុលាការ ដើម្បីបើកសវនាការធ្វើការជំនុំជម្រះតាមដីការបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅកាន់តុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា[61]។ ការឃុំខ្លួនអនីតិជន ដែលជាជនជាប់ចោទក្នុងពន្ធនាគារ គឺត្រូវអនុវត្តតាមនីតិវិធីនៃការឃុំខ្លួនជាបណ្ដោះអាសន្ន ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលមាន

[56] ច្បាប់ស្តីពីពន្ធនាគារ,មាត្រា ៤ ចំណុច ៣ ឆ្នាំ ២០១១
[57] ច្បាប់ស្តីពីពន្ធនាគារ,មាត្រា ២៦ ឆ្នាំ ២០១១
[58] នីតិព្រហ្មទណ្ឌទូទៅ,សាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៣៦
[59] ក្រមនីតិវិធីព្រហ្មទណ្ឌ,មាត្រា ២០៣ ឆ្នាំ២០០៧
[60] ក្រមនីតិវិធីព្រហ្មទណ្ឌ,មាត្រា ២០៤ ឆ្នាំ២០០៧
[61] ក្រមនីតិវិធីព្រហ្មទណ្ឌទូទៅ,សាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៣៥

ស្រាប់។ ចំពោះរយៈពេលនៃការឃុំខ្លួនវិញ ក៏មិនត្រូវឱ្យលើសពីរយៈពេលដូចដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។

**ពិរុទ្ធជន** ជាជនដែលតុលាការមិនទាន់បានកាត់ទោស ហើយត្រូវបានសន្មតថាគ្មានកំហុស។ ពិរុទ្ធជនអាចជាជនជាប់សង្ស័យ ឬជនជាប់ចោទ ក្នុងបទល្មើសណាមួយ ហើយត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំង ស្របច្បាប់តាមអំណាចដីការង់ចាំការសម្រេចពីតុលាការ[62]។ ក្រោយពីការជំនុំជំរះរួចហើយ ក៏ត្រូវរង់ចាំរយៈពេលមួយសម្រាប់ឱ្យសេចក្តីសម្រេចនោះ ចូលជាស្ថាពរផងដែរ ដើម្បីបញ្ចប់នូវនីតិវិធីតាមផ្លូវបណ្តឹងរបស់អនីតិជននេះទៅកាន់តុលាការជាន់ខ្ពស់។

**ទណ្ឌិត** ជាជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសរួច ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ[63]។ ការឃុំខ្លួនក្នុងពន្ធនាគារ ត្រូវអនុវត្តរហូតដល់រយៈពេលនៃការអនុវត្តទោសនោះត្រូវបានបញ្ចប់ ហើយកំឡុងពេលនៃការអនុវត្តទោសនេះដែរ ទណ្ឌិតជាអនីតិជនត្រូវគោរពនូវបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងស្តាប់តាមការណែនាំពីសំណាក់មន្ត្រីពន្ធនាគារ ឲ្យបានខ្ជាប់ខ្ជួនផងដែរ[64]។ ក្រៅពីការស្តាប់តាមការណែនាំ និងគោរពតាមបទបញ្ជាផ្ទៃក្នុងហើយ ក៏មានកាតព្វកិច្ចត្រូវធ្វើពលកម្ម ព្រមទាំងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារថែមទៀតផង។

ដូច្នេះ ស្ថានភាពឃុំឃាំងនៅក្នុងពន្ធនាគារដែលអនុវត្តចំពោះអនីតិជន បានធ្វើការបែងចែកជនត្រូវចោទ និងជនជាប់ចោទ ធ្វើឡើងស្របតាមនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដូចមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ រីឯចំពោះពិរុទ្ធជនវិញ ការឃុំខ្លួនអាចធ្វើទៅបានទាល់តែត្រូវរងចាំ សេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរជាមុនសិន ទើបអាចឃុំខ្លួនជននោះបាន។

ងាកមកមើល ទណ្ឌិតឯនេះវិញ ការឃុំខ្លួនត្រូវអនុវត្តរហូតដល់រយៈពេលនៃការឃុំខ្លួនត្រូវបានបញ្ចប់ ទើបអាចដោះលែងជននោះឲ្យមានសេរីភាពដូចដើមវិញបាន។

### ៣.១.២. ការអនុវត្តទោសពិន័យ

ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយប្រភេទដែលស្ថិតក្នុងឋានៈជាមូលទោស ហើយខុសពីទណ្ឌកម្មផ្សេងៗទៀតដែលចៅក្រមបានធ្វើការប្រកាសផ្តន្ទាទោស ពោលគឺសំដៅទៅលើទោសមួយប្រភេទ ដែលមានគោលដៅធ្វើឲ្យជនល្មើសនោះមានការរាងចាលតែម្តង[65]។ ដូច្នេះ ក្នុងករណីអនីតិជនម្នាក់បានប្រព្រឹត្តបទល្មើស

[62] ក្រមនីតិវិធីព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៦៧

[63] ក្រមនីតិវិធីព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៤០

[64] ច្បាប់ស្តីពីពន្ធនាគារ,មាត្រា ២០ ឆ្នាំ២០១១

[65] ទោសព្រហ្មទណ្ឌ, កៅ សីហា ទំព័រ ៤៤

ចៅក្រមអាចប្រកាសឲ្យអនីតិជននោះបង់សំណងចូលថវិការរដ្ឋផង និងសម្រេចឲ្យបង់សំណងរដ្ឋប្បវេណីទៅជនរងគ្រោះថែមទៀត។ ដើម្បីអាចធានាបាន នូវការបង់ប្រាក់ពិន័យធ្វើឡើងដោយអាជ្ញាធរតុលាការ។

**ការដាស់តឿនឲ្យបង់ប្រាក់ពិន័យ**[66]

ជាទូទៅ ប្រសិនបើដល់ការកំណត់ដែលត្រូវបង់ប្រាក់ពិន័យ ហើយទណ្ឌិតមិនបានបង់ទេនោះ អង្គភាពរតនាគារ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ក្រោយពីបានទទួលដំណឹងនេះហើយ ព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់មួយសម្រាប់ទុកដល់ទណ្ឌិតដែលជាអនីតិជននោះដើម្បីអោយបង់ប្រាក់ពិន័យ។ រីឯចំពោះរយៈពេលដែលព្រះរាជអាជ្ញាបានកំណត់នោះមិនអាចតិចជាង ១០ (ដប់) ថ្ងៃឡើយ។ មិនតែប៉ុណ្ណោះ ការជូនដំណឹងនេះទៀតសោតន៍ ចាំបាច់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថផងដែរ។ លើសពីនេះទៅទៀត ការឲ្យដំណឹងនេះត្រូវធ្វើជាកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយទណ្ឌិត ឬផ្តិតម្រាមដៃ ក្នុងករណីដែលទណ្ឌិតមិនចេះចុះហត្ថលេខា។

សូមបញ្ជាក់ផងដែរថា ទោះបីជាមានការជូនដំណឹងដោយព្រះរាជអាជ្ញា អំពីការដាស់តឿនឲ្យទណ្ឌិតដែលជាអនីតិជននោះ បង់ប្រាក់ពិន័យបែបនេះក៏ដោយ។ ដោយឡែក ក្នុងករណីដែលអនីតិជននោះ នៅតែមិនព្រមបង់ប្រាក់ពិន័យទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយចំពោះអនីតិជននោះបានឡើយ។

**ការរួចខ្លួនពីការបង្ខំដល់រូបកាយ**

ការបង្ខំដល់រូបកាយ ត្រូវអនុវត្តទៅលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ហើយដែលជននោះមិនបានបង់នូវប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណងជំងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាអាទិ៍។ ដូច្នេះដើម្បីធានាឲ្យបាននូវការបង់ប្រាក់ពិន័យ មានវិធានការពីរយ៉ាងដែលអាចលើកយកមកអនុវត្តបាន គឺ ការរឹបអូស និងការបង្ខំដល់រូបកាយ។ ជាគោលការណ៍វិធានការបង្ខំដល់រូបកាយ ត្រូវអនុវត្តទៅតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ៥២៣ រហូតដល់មាត្រា ៥៣៣។ រីឯវិធានការរឹបអូសទ្រព្យសម្បត្តិវិញ ត្រូវអនុវត្តទៅតាមបញ្ញត្តិ ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ គេសង្កេតឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់អំពីការបង្ខំដល់រូបកាយអាចធ្វើទៅបាន លុះត្រាតែទណ្ឌិតមានចេតនាគេចវេះ មិនព្រមបង់ប្រាក់ពិន័យឡើយ។ ក្នុងន័យនេះ អាចនាំឲ្យមានការបកស្រាយបានថា ការបង្ខំដល់រូបកាយដើម្បីទាមទារប្រាក់ពិន័យអាចប្រព្រឹត្តទៅបាន បើទោះបីជាទណ្ឌិតលើកសំអាងថា ខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ពិន័យក៏ដោយ[67]។ ក៏ប៉ុន្តែ ការបកស្រាយបែបនេះ នឹងធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់បុគ្គលដែលមានជីវភាពក្រីក្រ ហើយដែលពិតជាមិនមានលទ្ធភាពបង់ប្រាក់ពិន័យប្រាកដមែន និងនៅទីបំផុតបែរជាទទួលនូវការចាប់

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ,មាត្រា ៥២៥ ឆ្នាំ២០០៧

[67] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ៤៥១

ដាក់ពន្ធនាគារដោយសារតែមូលហេតុនេះ។ ហេតុដូច្នេះ ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងយ៉ាងជាក់លាក់តម្រូវឲ្យមានការគេចវេះដោយចេតនាក្នុងការបង់ប្រាក់ពិន័យ ដើម្បីអាចបង្ខំដល់រូបកាយបានក៏ដោយ ក៏គួរគប្បីកំណត់ជាយុត្តិសាស្ត្រនូវលក្ខខណ្ឌនេះ ដើម្បីធានាឲ្យមាននូវការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់បុគ្គលដែរ[68]។

ដោយឡែកក្នុងករណីនេះ ច្បាប់ក៏បានបញ្ញត្តិយ៉ាងជាក់លាក់ផងដែរថា ការបង្ខំដល់រូបកាយគឺមិនអាចអនុវត្តទៅលើទណ្ឌិតជាអនីតិជនបានឡើយ នៅពេលដែលបានប្រព្រឹត្តិបទល្មើស[69]។ មានន័យថា ការណ៍ដែលច្បាប់បានកំណត់បែបនេះ អាស្រ័យដោយហេតុថា អនីតិជនជាជនដែលស្ថិតនៅក្នុងវ័យមួយកំពុងមានការរីកលូតលាស់នៅឡើយ ប្រសិនបើអនុញ្ញាតឱ្យមានការអនុវត្តការបង្ខំដល់រូបកាយនោះ និងបង្កឲ្យមានផលប៉ះពាល់ដល់ការវិវត្តរបស់ពួកគេជាមិនខាន។ លើសពីនេះទៅទៀត ក៏អាចបណ្តាលឲ្យពួកគេមាននូវស្លាកស្នាមអាក្រក់ជិតដាមជាប់ក្នុងអារម្មណ៍ និងជះឥទ្ធិពលដល់ការរស់នៅ ព្រមទាំងការវិវត្តរបស់ពួកគេទៅថ្ងៃអនាគតផងដែរ។

### ៣.១.៣. ការអនុវត្តទោសក្នុងមណ្ឌលយុវនីតិសម្បទា

គេសង្កេតឃើញថា ការបែងចែកការឃុំខ្លួនអនីតិជននៅក្នុងពន្ធនាគារទៅតាមប្រភេទដូចខាងលើនេះ គឺមានលក្ខណៈខុសប្លែកគ្នាពីការអនុវត្តទោស ចំពោះអនីតិជននៅក្នុងមណ្ឌលនីតិសម្បទាដោយការអនុវត្តទោសចំពោះអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបានបែងចែកជាបីផ្នែកដូចខាងក្រោមវិញគឺ[70]៖

ក. ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន

ខ. ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលយកកម្មវិធីស្តារនីតិសម្បទានិង

គ. ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម

មួយវិញទៀត ក្រៅពីការបែងចែកផ្នែកសម្រាប់គ្រប់គ្រងអនីតិជននេះហើយ ក៏ត្រូវរក្សាអនីតិជននេះដាក់នៅដោយឡែកពីនីតិជនផងដែរ ពោលគឺត្រូវដាក់ក្នុងអាគារដាច់ដោយឡែកទៅតាមភេទផ្សេងៗគ្នា តាមប្រភេទនិងស្ថានភាពនៃបទល្មើស អាយុ អត្តចរិក សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់អនីតិជននោះ។ ចំពោះអនីតិជនភេទស្រីវិញ ត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកដែលមានភេទដូចស្រីដូចគ្នា។ រីឯក្នុងករណីអនីតិជនដែលមានជំងឺឆ្លងវិញ ត្រូវនៅក្នុងអាគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដោយឡែកពីអនីតិជនផ្សេងៗជាកំហិត។ ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលនឹងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទា

[68] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ៤៤៨

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ,មាត្រា ៥៣១ ឆ្នាំ២០០៧

[70] ច្បាប់ស្តីយុត្តិធម៌អនីតិជន, មាត្រា ៧៧ ឆ្នាំ ២០១៦

បន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមជ្ឈមណ្ឌលឃុំឃាំងសម្រាប់នីតិជនវិញ។ ចំពោះបែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវពិនិត្យដោយប្រកាសដោយអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[71] ។

មន្ត្រីមណ្ឌលឃុំវនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រង អនីតិជន ត្រូវទទួលការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ហើយមណ្ឌលឃុំវនីតិសម្បទានេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ចំណែកឯការរៀបចំ និងការប្រព្រឹត្តរបស់មណ្ឌលក៏ត្រូវកំណត់ដោយអនុក្រឹត្យ។

ចំណែកឯការចុះឈ្មោះអនីតិជនក្នុងបញ្ជី គ្រប់មណ្ឌលឃុំវនីតិសម្បទាត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាអោយមានសុវត្ថិភាព។ បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អនីតិជនដែលជាប់ឃុំនៅក្នុងមណ្ឌលឃុំវនីតិសម្បទាទាំងអស់ត្រូវទទួលបានសិទ្ធិមូលដ្ឋានដូចតទៅ[72]៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និង ផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ទណ្ឌកម្មរួមមាន ការដាក់អោយនៅឯកា ការដាក់កំហិត ឬបដិសេធ មិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូរបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែង ទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជម្ងឺ ឬរបួស និងផ្តល់ដំណឹងដល់ពុកម្តាយ ឬអាណាព្យាបាល សម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ អ្នកទំនុកបម្រុង និងមេធាវី

[71] ច្បាប់ស្តីពីយុត្តធម៌អនីតិជន, មាត្រា៨២ ឆ្នាំ២០១៦

[72] ច្បាប់ស្តីពីយុត្តធម៌អនីតិជន, មាត្រា៨០ ឆ្នាំ២០១៦

- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ និងមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងការឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។

**ការធ្វើអធិការកិច្ចមណ្ឌលឃុំនីតិសម្បទា**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលឃុំនីតិសម្បទាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួន ត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន។ យន្តការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលឃុំនីតិសម្បទានានាបានគ្រប់ពេល។ លើសពីនេះទៅទៀត អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចជា [73]៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដែលស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ អាយុ របស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡាកម្សាន្ត និងសម្រាកពីការងារ
- សុខភាពផ្លូវកាយ សុខភាពផ្លូវចិត្តឲ្យបានសមរម្យ
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ដែលត្រូវការបញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនៃព័ត៌មាន អំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពីការភាពផ្អែកកាយសម្បទា ឬពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងៗទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានការទទួលខុសត្រូវ អោយមានអាកប្បកិរិយា និងជំនាញ ដែលនឹងជួយអនីតិជនមានការអភិវឌ្ឍសក្តានុពលរបស់ខ្លួន ក្លាយជាពលរដ្ឋម្នាក់ក្នុងសង្គម និងជួយសង្គមឲ្យបានល្អប្រសើរត្រឡប់មកវិញ បន្ទាប់ពីមានការដោះលែងរួចហើយ។

[73] ច្បាប់ស្តីពីយុត្តធម៌អនីតិជន, មាត្រា៨១ ឆ្នាំ២០១៦

### ៣.២. ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវធ្វើឡើងដោយផ្អែកលើអត្តចរឹក (៣.២.១) និងការដោះលែងតាមការស្នើសុំ (៣.២.២) ចំពោះការដោះលែងដោយមានលក្ខខណ្ឌ។

#### ៣.២.១. ការដោះលែងដោយផ្អែកលើអត្តចរឹក

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទា ដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន[74]។

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតដែលជាអនីតិជនទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា[75]៖

- ទណ្ឌិតបានបំពេញទោសចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ (មួយ)ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត។

#### ៣.២.២. ការដោះលែងដោយផ្អែកលើតាមការស្នើសុំ

ដើម្បីលើកឡើងឲ្យមានការដោះលែងដោយមានលក្ខខណ្ឌ យកមកអនុវត្តបាន ច្បាប់បានកំណត់ដោយបុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយលក្ខខណ្ឌ រួមមាន[76]៖

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់អនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវជីតិសម្បទា
- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ
- បេសកកម្មទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស។

ការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវផ្តល់ដោយប្រធានតុលាការជាន់ដំបូងនៃកន្លែងឃុំខ្លួន។ បន្ទាប់ពីទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូងត្រូវបញ្ជូនទៅគណៈកម្មការជាតិនូវពាក្យសុំ សាលក្រម ឬសាលដីកា ផ្តន្ទាទោស ជាយថាហេតុ សាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិត ទទួលទោសច្រើន ព្រឹត្តិបត្រលេខ ១ (មួយ) នៃបញ្ជីថ្កោលទោស យោបល់ព្រះរាជអាជ្ញា និងគ្រប់លិខិតទាំង

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា៥១២ ឆ្នាំ២០០៧

[75] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា៧២ ឆ្នាំ២០១៦

[76] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា៧៣ ឆ្នាំ២០១៦

អស់ដែលមាន ប្រយោជន៍ បន្ទាប់មក គណៈកម្មការជាតិត្រូវបញ្ចេញយោបល់របស់ខ្លួនជាលាយលក្ខណ៍អក្សរ នឹងមានសំអាងហេតុក្នុងរយៈពេលខ្លីបំផុតទៅកាន់ប្រធានតុលាការជាន់ដំបូងភ្លាម [77] ។ ប្រធានតុលាការត្រូវសម្រេចដោយមានសំអាងហេតុ ក្រោយពីទទួលបានយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។ រាល់សេចក្តីសម្រេចរបស់ប្រធានតុលាការ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បាន ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយបណ្តឹងតវ៉ានេះ អាចឡើងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាសាមីតែប៉ុណ្ណោះ។ នៅពេលប្រធានតុលាការជាន់ដំបូងបង្គាប់ឲ្យមានការដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់អំពីការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត ដោយកំណត់រយៈពេលសាកល្បង ដែលមិនអាចលើសពីថេរវេលានៃទោសដែលនៅសល់មិនទាន់ទទួលរងឡើយ។ ផ្ទុយទៅវិញ ក្នុងករណីដែលមានការផ្តន្ទាទោសសារជាថ្មី ឬការមិនគោរពលក្ខខណ្ឌដែលបានកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្តីសម្រេចរបស់ខ្លួនវិញបាន ដែលនាំឱ្យទណ្ឌិតត្រូវទទួលទោសដែលនៅសល់។ ប្រសិនបើទណ្ឌិតបានគោរពទៅតាមដីកា ឬមិនបានផ្តន្ទាទោសចំពោះបទល្មើសថ្មីទេ ហើយមិនត្រូវបានដកហូតសេចក្តីសម្រេចក្នុងរយៈពេលសាកល្បងទេ លុះផុតរយៈពេលនៃការកំណត់នោះ ការដោះលែង នឹងក្លាយជាស្ថាពរ។

## ៣.៣. ការស្តារនីតិសម្បទាឡើងវិញ

បន្ទាប់ពីអនីតិជនបានអនុវត្តទោសរួចចប់សព្វគ្រប់ហើយ ឬនៅពេលអាជ្ញាយុកាលនៃទោសត្រូវបានផុត ច្បាប់បានតម្រូវឲ្យមានការផ្តល់ និងការមាននីតិសម្បទាឡើងវិញចំពោះអនីតិជនដែលអាចមានលក្ខខណ្ឌជា ការស្តារនីតិសម្បទាឡើងវិញតាមផ្លូវតុលាការ និងការស្តារនីតិសម្បទាឡើងវិញតាមច្បាប់កំណត់ ។

### ៣.៣.១. ការស្តារនីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឲ្យ ឬមិនត្រូវបានផ្តល់ឲ្យ ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។ ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបានដោយទណ្ឌិតជានីតិជន ដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន ឬធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន។ លក្ខខណ្ឌលើរយៈពេលទាក់ទងទៅនឹងពាក្យសុំឲ្យមានការសុំផ្តល់ នីតិសម្បទាឡើងវិញអាចធ្វើទៅបានលុះត្រាតែផុតរយៈពេលដូចតទៅ[78]៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា៥១៥ ឆ្នាំ២០០៧

[78] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា៧៤ ឆ្នាំ២០១៦

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល។ លើសពីនេះទៅទៀតការមិនបង់ប្រាក់ពិន័យ ប្រាក់ពាក់ព័ន្ធនៃនីតិវិធី ឬប្រាក់សំណង និងជំងឺចិត្តមិនមែនជាឧបសគ្គដល់ការឲ្យមាននីតិសម្បទារឡើងវិញទេ ប្រសិនបើទណ្ឌិតផ្តល់ជូនភស្តុតាងថាខ្លួនស្ថិតនៅភាពអសាធន៍[79]។ អនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដី ហើយត្រូវចង្អុលបង្ហាញប្រភេទទណ្ឌកម្មដែលខ្លួនបានរង បញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ។ បន្ទាប់ពីទទួលបានពាក្យសុំហើយព្រះរាជអាជ្ញា ចាប់ផ្តើមធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែងដែលទណ្ឌិតជាអនីតិជនធ្លាប់បានរស់នៅតាំងពីពេលដែលខ្លួនត្រូវបានដោះលែង។ ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងដែលមានយោបល់ និងសំអាងហេតុរបស់ខ្លួនភ្ជាប់ទៅជាមួយអង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់មកអង្គព្រះរាជអាជ្ញាប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ហើយជូនដំណឹងអំពីការបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសុំ និងមេធាវី។ បន្ទាប់ពីទទួលពាក្យប្តឹងបណ្តឹងពីអគ្គព្រះរាជអាជ្ញា តុលាការត្រូវសម្រេចនៅពេលសម្រាកសាធារណៈ ក្រោយពីបានស្តាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា[80]។ ក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុតរយៈពេល២ (ពីរ) ឆ្នាំ បានឡើយ។ ប្រសិនបើពាក្យសុំលើកទីមួយត្រូវតុលាការបដិសេធ ដោយសារការមិនគ្រប់រយៈពេល ពាក្យសុំអាចធ្វើថ្មីបានចាប់ពីការផុតកំណត់ផុតរយៈពេលនោះ។

### ៣.៣.២. ការស្តារនីតិសម្បទាឡើងវិញតាមច្បាប់កំណត់

នីតិសម្បទាមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល[81]៖

- ៣ (បី) ឆ្នាំចំពោះបទឧក្រិដ្ឋ
- ១ (មួយ) ឆ្នាំចំពោះបទមជ្ឈិម
- ៣ (បី) ខែចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវបានផុតអាជ្ញាយុកាល។ អនីតិជនដែលទទួលបាននីតិសម្បទាឡើងវិញ ត្រូវបានលុបលាងចោលទណ្ឌកម្មព្រហ្មទណ្ឌទាំងអស់ ហើយត្រូវបានគេលុបចេញពីបញ្ជីថ្កោលទោស។ កំណត់ហេតុ និងសំណុំរឿងឯកសារដទៃទៀតរបស់អនីតិជនត្រូវបានរក្សាជាសម្ងាត់។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៥៣៦ កថាខណ្ឌទី២

[80] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៥៣៩

[81] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា៧៥ ឆ្នាំ២០១៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវ នូវប្រធានបទខាងលើរួចរាល់ហើយមក យើងខ្ញុំឃើញថានៅពេលអនីតិជន ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលបានកំណត់ដោយច្បាប់នោះ អនីតិជនដែលបានប្រព្រឹត្តគឺ មិនអាចរួចផុតពី ការអនុវត្តទោសព្រហ្មទណ្ឌទាំងស្រុងបាននោះទេ គ្រាន់តែមានលក្ខខណ្ឌពិសេសមួយចំនួន ដែលត្រូវបានបញ្ញត្តិ ដាច់ដោយឡែកគឺ "**ច្បាប់ស្តីពីអនីតិជន**" ដើម្បីយកមកធ្វើការអនុវត្តទៅលើជនល្មើស ក៏ដូចជាជនត្រូវចោទដែល ជាអនីតិជន។ ប៉ុន្តែដោយហេតុថា អនីតិជនគឺស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ ដែលពួកគេស្ថិតនៅក្នុងវ័យ កំពុងលូតលាស់ផ្នែកចិត្តគំនិត ប្រាជ្ញាស្មារតី និងការគិតពិចារណារបស់ពួកគេនៅមានភាពក្មេងខ្ចីនៅឡើយ។ ដែល កត្តាទាំងអស់នេះហើយ បានធ្វើឲ្យអនីតិករចាំបាច់ធ្វើការពិចារណាទៅលើចំណុចមួយចំនួន ដើម្បីអាចកំណត់ បានថា តើអនីតិជននោះមានលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌហើយឬនៅ? ចំណុចទាំងនោះរួមមាន ដូចជា កត្តាអាយុ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជន។ ចៅក្រម និងតំណាង អយ្យការត្រូវយកកត្តាទាំងអស់នេះមកពិចារណាឲ្យបានល្អិតល្អន់ និងម៉ត់ចត់បំផុតមុននឹងធ្វើការសន្និដ្ឋានថា អនីតិជន ត្រូវទទួលខុសត្រូវ ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ? ព្រោះថា ប្រសិនបើគ្មានការពិចារណាអោយបានល្អិតល្អន់ ទេនោះ វានឹងអាចជះឥទ្ធិពលអាក្រក់ទៅលើអនាគតរបស់អនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាខ្លាំង។ ម្យ៉ាងវិញទៀត ចំពោះការអនុវត្តទោសព្រហ្មទណ្ឌលើអនីតិជន ច្បាប់ស្តីពីអនីតិជនបានបញ្ញត្តិនូវវិធានការពិសេស មួយ គឺវិធានការបង្វែរដែលវិធានការនេះមានគោលបំណងលើកទឹកចិត្ត ជៀសវាងនូវស្នាមអាក្រក់ក្នុងអារម្មណ៍ របស់អនីតិជន និងបង្កឲ្យទៅជាមានការរើសអើង ក៏ដូចជាប្រវត្តិជាប់ពន្ធនាគារក្នុងបញ្ជីថ្កោលទោសជាអាទិ៍។

សរុបជារួមមក នីតិវិធីនៃការអនុវត្តរឿងក្តីព្រហ្មទណ្ឌដែលមានជនត្រូវចោទជាអនីតិជនគឺមានលក្ខណៈ ពិសេសខុសពីនីតិជន ដែលលំហូរនៃនីតិវិធីនេះទៀតសោតត្រូវបានបញ្ញត្តិក្នុងច្បាប់អនីតិជន ក្នុងគោលបំណង ដើម្បីផ្តល់ឲ្យអនីតិជននូវឧត្តមប្រយោជន៍នានា ក៏ដូចជាសិទ្ធិមូលដ្ឋានទាំងឡាយដែលអនីតិជនត្រូវតែទទួលបាន នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធីចំពោះរឿងក្តីព្រហ្មទណ្ឌ។ ការបញ្ញត្តិនូវនីតិវិធីពិសេសបែបនេះគឺបាន ផ្តល់នូវផលវិជ្ជមានជាច្រើន សម្រាប់ជនត្រូវចោទដែលជាអនីតិជន ជាពិសេសគឺផ្តល់ឱកាសសម្រាប់ការស្តារមក វិញនូវនីតិសម្បទា និងការសម្របខ្លួនត្រឡប់ទៅក្នុងសង្គមវិញ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសង្កេតឃើញថា សិទ្ធិរបស់អនីតិជន ត្រូវបានការពារក្រោមច្បាប់ជាតិ និងអន្តរជាតិ ប៉ុន្តែច្បាប់ដែលពាក់ព័ន្ធនឹងកុមារហាក់បីដូចជាមិនមានភាពទូលំទូលាយក្នុងការគាំពារកុមារឲ្យទទួលបានសិទ្ធិ ដែលពួកគេគួរទទួលបាននោះទេ។ ដោយសារហេតុនេះនៅពេលមានការអនុវត្តទោសចំពោះអនីតិជនមិនថាជាទោសពិន័យ ឬទោសជាប់ឃុំក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ជាគោលការណ៍មានលក្ខណៈស្របទៅតាមច្បាប់ជាតិ និងអន្តរជាតិ ជាពិសេសស្របតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលធានារក្សាការពារផលប្រយោជន៍របស់អនីតិជនជាចម្បង ប៉ុន្តែទោះបីជាច្បាប់បានកំណត់ដូច្នេះក៏ដោយចំពោះករណីមួយចំនួនក៏នៅតែមានការរំលោភបំពានសិទ្ធិមួយចំនួនលើអនីតិជនផងដែរ។ បញ្ហាទាំងនេះគឺជា បញ្ហាចោទយ៉ាងសំខាន់ហើយក៏ជាកាតាលីករមួយដែលនាំឲ្យមានការរាំងស្ទះការអនុវត្តបញ្ញត្តិច្បាប់ ដែលពាក់ព័ន្ធនឹងអនីតិជនឲ្យបានកាន់តែមានប្រសិទ្ធិភាពផងដែរ។

ហេតុនេះហើយ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះបានគឺ ទាមទារឲ្យមានដំណោះស្រាយប្រកបទៅដោយការយកចិត្តទុកដាក់មួយចំនួនដូចជា៖

- បង្កើតតុលាការជំនាញរឿងក្តីព្រហ្មទណ្ឌអនីតិជនដែលមានមន្ត្រីជំនាញមានសមត្ថកិច្ចធ្វើការដោះស្រាយរឿងក្តីអនីតិជន។
- ផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធទៅនឹងអនីតិជនឲ្យបានទូលំទូលាយ ទៅគ្រប់មជ្ឈដ្ឋានទាំងអាជ្ញាធរ និងប្រជាពលរដ្ឋ ក៏ដូចជាអង្គការក្នុងស្រុកនានា។
- ពង្រឹងការអនុវត្តន៍នីតិវិធីនៅគ្រប់ដំណាក់កាល និងត្រូវប្រាកដថា នីតិវិធីដែលប្រព្រឹត្តទៅលើអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈជានីតិវិធីកុមារមេត្រី។
- ជម្រុញ និងលើកទឹកចិត្តទៅដល់ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធទាំងឡាយឲ្យមានការពិចារណាជាបឋមទៅលើការប្រើប្រាស់នូវវិធានការបង្វែរមុននឹងឈានដល់ការសម្រេចដាក់នូវទណ្ឌកម្មព្រហ្មទណ្ឌ។
- ប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវធ្វើការណែនាំមន្ត្រីពន្ធនាគារនៅតាមតំបន់សមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួនចំពោះការដាក់ជាប់ឃុំដែលជាអនីតិជន ដោយនៅដាច់ដោយឡែកពីនីតិជនដោយយកចិត្តទុកដាក់បំផុត។

# ឯកសារយោង

## ឯកសារយោង

### ១. ច្បាប់ និងលិខិតបទដ្ឋាន

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ០២០៨/ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រ១១០៩ /០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ០៨០៧/ ០២៤/ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ០៧១៦/ ០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
- ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ០៧១៦ /០០៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

### ២. ច្បាប់ និងលិខិតបទដ្ឋានអន្តរជាតិ

- អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ២០០៩

### ៣. សៀវភៅ និងស្នាដៃនិពន្ធ

- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៨
- លោក កៅ សីហា ទោសព្រហ្មទណ្ឌ ឆ្នាំ២០១១
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ២០១២

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ កំណត់ហេតុសួរចម្លើយ

ឧបសម្ព័ន្ធទី២ ៖ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ឧបសម្ព័ន្ធទី៣ ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ឧបសម្ព័ន្ធទី៤ ៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ឧបសម្ព័ន្ធទី៥ ៖ ដីកាសន្និដ្ឋានស្ថាពរ

ឧបសម្ព័ន្ធទី៦ ៖ សារាចរ

# ឧបសម្ព័ន្ធទី១

# កំណត់ហេតុសួរចម្លើយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
..........

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៥
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

# កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ ដោយមានលោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជិកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយការុក សង្កាត់កលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (ស្លាប់) ជាអនីតិជន ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្ដាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 ភ្លើង ពណ៌ក្រហម ទៅឈ្មោះ ខ្ចីយកជិះទៅធ្វើសកម្មភាពគាស់ទ្វារផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរស័ព្ទហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្ដង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូបខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតម្រាមដៃជាមួយយើង។

| | | |
|---|---|---|
| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |

# ឧបសម្ព័ន្ធទី២

# ដីកាសម្រេចឃុំខ្លួន

# បណ្ដោះអាសន្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត រាជធានី

សំណុំរឿងព្រហ្មទណ្ឌលេខ............

ចុះថ្ងៃទី...........................................

សំណុំរឿងស៊ើបសួរលេខ...................

ចុះថ្ងៃទី.........................................

លេខ[1]..........................................

# ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង.........................................ចៅក្រមស៊ើបសួរនៃសាលាដំបូង............................អមដោយ លោក/លោកស្រី..........................................ជាក្រឡាបញ្ជី។

- បានឃើញមាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.............ចុះថ្ងៃទី........ខែ.........ឆ្នាំ............. ដែលបានបើកការស៊ើបសួរលើ

ឈ្មោះ...............................ឈ្មោះហៅក្រៅ.......................ភេទ........ថ្ងៃខែឆ្នាំកំណើត........................

សញ្ជាតិ...............មុខរបរ.........................មានអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ.....................

កំរិតវប្បធម៌..............................ទីកន្លែងកំណើតនៅភូមិ.............................ឃុំ/សង្កាត់.......................

ស្រុក/ខណ្ឌ..........................ខេត្ត/រាជធានី...................................។

ទីលំនៅផ្ទះលេខ.........................ផ្លូវលេខ..................ភូមិ...............................ឃុំ/សង្កាត់.......................

ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត..................។

ឪពុកឈ្មោះ.........................................រ☐ ស☐ ម្ដាយឈ្មោះ.........................................រ☐ ស☐

ប្ដី/ប្រពន្ធឈ្មោះ..............................រ☐ ស☐ មានកូន.......នាក់ ឬនៅលីវ☐ នីតិជន☐ អនីតិជន☐។

មុខរបរ...............................................

[1] លេខរបស់ដីកាសម្រេច

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.............................................................................................។

ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ..............................តាមមាត្រា..............................

នៃក្រមព្រហ្មទណ្ឌ/ច្បាប់..............................................................................................................។

ប្រព្រឹត្តនៅផ្ទះលេខ..............................ផ្លូវលេខ..............ភូមិ..............................ឃុំ/សង្កាត់..................

ស្រុក/ខណ្ឌ..............................ខេត្ត/រាជធានី.............................................................................

កាលពីថ្ងៃទី..................ខែ..................ឆ្នាំ..............។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី

## I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១ ក្នុងករណីបច្ចុប្បន្ន ជនត្រូវចោទឈ្មោះ ..............................ត្រូវចោទពីបទ..............................

(បញ្ចូលបទល្មើសដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ..............)

២. ប្រព្រឹត្តិនៅ.................................................................................................................

(សង្ខេបអង្គហេតុនៃរឿង)

៣. តំណាងអយ្យការ បានស្នើឲ្យឃុំខ្លួន☐ មិនឲ្យឃុំខ្លួន☐ បណ្តោះអាសន្នលើជនត្រូវចោទ

ឈ្មោះ..............................ផ្អែកលើសំអាងហេតុដូចតទៅ..............................

.................................................................................................................

.................................................................................................................

.................................................................................................................

៤. ជនត្រូវចោទឈ្មោះ ..............................ឬមេធាវីការពារ ស្នើសុំ(កូនក្តីឲ្យ)នៅក្រៅឃុំ

បណ្តោះអាសន្ន☐ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ☐ ដោយសំអាងហេតុផលថា

.................................................................................................................

.................................................................................................................

.................................................................................................................

## II. សំអាងហេតុនៃសេចក្តីសម្រេច

៥. ជនត្រូវចោទឈ្មោះ..............................ត្រូវចោទពីបទឧក្រិដ្ឋ/មជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦. (បញ្ចូលនូវការយល់ឃើញឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលលើកឡើងដោយភាគីមាន ដូចជា តំណាងអយ្យការ និងជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ ដោយពន្យល់សំអាងហេតុ គាំទ្រទៅនឹងមូលហេតុនៃការឃុំខ្លួន ចំនួនមួយ ឬច្រើន ដែលមានចែងក្នុងមាត្រា២០៥ នៃក្រម នីតិវិធីព្រហ្មទណ្ឌ)..........................................................................................................

..........................................................................................................

..........................................................................................................

(ហេតុផលជាមូលដ្ឋានពីថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន និងមានយោងតាមបញ្ញត្តិច្បាប់)

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និងអាច ធានាឲ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយ មានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

## ហេតុដូច្នេះ សម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ..............................ជាបណ្ដោះអាសន្នរយៈពេលអតិបរមា............។

ធ្វើនៅ..............ថ្ងៃទី........ខែ...........ឆ្នាំ.........

ចៅក្រមស៊ើបសួរ

ក្រឡាបញ្ជី

## លិខិតបញ្ជូន

យើង.................................បានប្រគល់ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ..........

ចុះថ្ងៃទី........ខែ............ឆ្នាំ..........

ដល់ឈ្មោះខាងក្រោម នៅថ្ងៃទី........ខែ......... ឆ្នាំ...............

អ្នកប្រគល់

អ្នកទទួល

| | | |
|---|---|---|
| តំណាងអយ្យការ | មេធាវីជនត្រូវចោទ | ជនត្រូវចោទ |

**សំគាល់៖** *តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា៖*

*ជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា២៦៧ និងមាត្រា២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។*

# ឧបសម្ព័ន្ធទី៣

# ដីកាសន្និដ្ឋានបញ្ជូនរឿង

# ឲ្យស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ចូល ថ្ងៃទី 12 ខែ 5 ឆ្នាំ 17

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ២៩៧៥
ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៧
លេខ:....១៤១៤២....អ.យ.រ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង **សេង ហៀង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៧៥ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ របាយការណ៍សំយោគលេខ ១៣៨/១៧ រ.ប.ក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា មានតម្រុយសន្មតបានថា៖**

១-នាមត្រកូល-នាមខ្លួន [illegible] ភេទ ប្រុស អាយុ ១៧ឆ្នាំ (២០-៤-២០០០) ជនជាតិខ្មែរ កើតនៅសង្កាត់ ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន ផ្ទះជួលគ្មានលេខ ផ្លូវ រទេះភ្លើង សង្កាត់ ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ សិស្សថ្នាក់ទី៩ នៅលើវ ឪពុកឈ្មោះ [illegible] "រស់" ម្ដាយឈ្មោះ [illegible] "រស់" ទោសពីមុន-គ្មាន ជាអនីតិជន។ (ឃាត់ខ្លួន)

២-ឈ្មោះ [illegible] ភេទ ប្រុស អាយុប្រហែល ២៧ឆ្នាំ។ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ[២]៖**

កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ វេលាម៉ោង ០៣និង៣០នាទីរំលងអាធ្រាត្រ នៅចំណុចមុខផ្ទះលេខ ៣៥អឺ០ ផ្លូវ ៣០៤ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ មានករណីលួច (ប៉ុនប៉ង) មួយបានកើតឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ [illegible] ភេទ ប្រុស អាយុប្រហែល ២៧ឆ្នាំ និងឈ្មោះ [illegible] ភេទ ប្រុស អាយុ ១៧ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរី២០១៧ ពាក់ស្លាកលេខ ភ្នំពេញ GG-8403 ធ្វើសកម្មភាពឆក់កាបូបពីជនរងគ្រោះ ដោយឈ្មោះ [illegible] ជាអ្នកលូកដៃឆក់កាបូប តែជនរងគ្រោះបានដឹងខ្លួនទាន់ ទាញកាបូបមកវិញ ហើយស្រែកចោរៗ ផ្អើលដល់សមត្ថកិច្ចល្បាតបានមកអន្តរាគមន៍ទាន់ពេលឃាត់បានជនសង្ស័យឈ្មោះ [illegible] រួមទាំងវត្ថុតាង បញ្ជូនទៅអធិការដ្ឋាននគរបាលខណ្ឌចំការមន ដើម្បីចាត់ការតាមនីតិវិធី ចំណែកជនសង្ស័យឈ្មោះ [illegible] បានរត់គេចខ្លួនបាត់។

[២] សេចក្ដីសង្ខេបអង្គហេតុ

អំពើខាងលើជាបទល្មើស *លួច (ប៉ុនប៉ង)* ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ផ្លូវលេខ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

**ហេតុដូច្នេះសម្រេច**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

☑ ដាក់អោយស្ថិតនៅក្រោមការពិនិត្យ[៣]៖

១-ឈ្មោះ ភេទ ប្រុស អាយុ ១៧ឆ្នាំ។ (ឃាត់ខ្លួន)

២-ឈ្មោះ ភេទ ប្រុស។ (គេចខ្លួន)

ពីបទ *លួច (ប៉ុនប៉ង)* ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ផ្លូវលេខ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ តាមមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៤]៖

-ឈ្មោះ ភេទ ប្រុស អាយុ ១៧ឆ្នាំ។ (ឃាត់ខ្លួន)

ពីបទ *លួច (ប៉ុនប៉ង)* ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ផ្លូវលេខ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ តាមមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ៕

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៧

ព្រះរាជអាជ្ញា

សេង ហៀង

ព្រះរាជអាជ្ញារង

[៣] ឈ្មោះជនត្រូវចោទ

# ឧបសម្ព័ន្ធទី៤
# ដីកាសម្រេចបញ្ជូន
# សំណុំរឿងទៅជំនុំជម្រះ

៧០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ៤១ ដ.ជ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៨ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នលេខ ៦៦៦, ៦៦១, ៦៦៧(ក) ដ.ឃ.ជ ចុះថ្ងៃទី....១៤.... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលើវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ . ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (ស) នៅលើវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៨.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រូស ឃុំក្រូស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិក្រូស ឃុំក្រូស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្ដីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ជាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៨១ឰE០ ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៦
ជ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦
ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញារង

# ឧបសម្ព័ន្ធទី៥

# ដីកាសន្និដ្ឋានស្ថាពរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥
លេខ: ៦៣ អ.យ.ទ

# ដីកាសន្និដ្ឋានស្ថាពរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ២៥៩៨ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ២១១៦៩ ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា

១. ពោក្តនាម-នាម ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅ លីវ ឪពុកឈ្មោះ ស្លាប់-ម្តាយឈ្មោះ រស់-ទោសពីមុនគ្មាន-ជា<u>អនីតិជន</u>។

២.ពោក្តនាម-នាម ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) កើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ (រ) កូនគ្មាន ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ជានីតិជន ទោសពីមុនគ្មាន។

៣.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៤.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៥.ឈ្មោះ ភេទប្រុស(គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយពារុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅ លីវ ឪពុកឈ្មោះ រស់-ម្តាយឈ្មោះ ស្លាប់-ទោសពីមុន-គ្មាន-ជាអនីតិជន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧. ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តីឈ្មោះ ហៅ (រ) កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

ឃើញថា

កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣ម១៥នាទី ទាបភ្លឺជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ, ឈ្មោះ ហៅ , ឈ្មោះ ឈ្មោះ និង ឈ្មោះ បានជិះម៉ូតូម៉ាក CITY 100PLUS ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ... ... ភេទប្រុស អាយុ១៥ឆ្នាំ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពយកឡូឌីសផ្តិះសោរទ្វារខាងមុខ ចំណែកជនត្រូវចោទឈ្មោះ បានផ្តិះសោរទ្វាខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ចំនួនប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនត្រូវចោទបានគេចខ្លួនទៅផ្ទះរបស់ជនត្រូវចោទឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន១លានរៀល។ ក្រោយមកជនត្រូវចោទឈ្មោះ បានយកប្រាក់ចំនួន៨ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ។ ចំណែកជនត្រូវចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការ

ស្រាវជ្រាវ ហើយឃាត់ខ្លួនជនត្រូវចោទពីរនាក់បានឈ្មោះ និង ឈ្មោះ ព្រមទាំងវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

បានឃើញរបាយការណ៍សំយោគលេខ ២០៩/១៥ ស.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ជនត្រូវចោទឈ្មោះ (ឃាត់ខ្លួន) និងបក្ខពួកឈ្មោះ ,ឈ្មោះ . ឈ្មោះ និង ឈ្មោះ (គេចខ្លួន) ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស កាលពីវេលាម៉ោង ០៣ម១៥នាទី រំលងអធ្រាត្រឈានចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនស៊ីហ្គាទេសចរណ៍ និង ពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ ២០១៥ ពិតប្រាកដមែន។ ចំណែកជនត្រូវចោទឈ្មោះ (ឃាត់ ខ្លួន) ពិជាបានសមគំនិត ផ្តល់ជាបញ្ជាបាយធ្វើសកម្មភាព និង ទទួលផលចោរកម្ម ក្នុងករណីនេះប្រាកដមែន រីឯឈ្មោះ (គេចខ្លួន) ដែលជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្ម ក្នុងករណីនេះផងដែរ។

បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ... បានឆ្លើយនៅសមត្ថកិច្ចថា ៖កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុនរបស់ខ្លួន មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសំរាកនៅផ្ទះ។ លុះដល់ម៉ោងប្រហែល ០៨ម០០នាទី ទៀបភ្លឺចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសំរាក ក៏មានសមត្ថកិច្ចទូរស័ព្ទមកប្រាប់ខ្លួនថា ក្រុមហ៊ុនរបស់ខ្លួនត្រូវបានចោរគាស់ទ្វារ ពេលនោះ ខ្លួនក៏បានមកមើល ទើបដឹងថា បាត់ទូដែកចំនួន០១ ហើយក្នុងទូដែកនោះមានប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន ២លានរៀល ឯកសារប្លង់ដីមួយចំនួន សៀវភៅធនាគារចំនួន០៣ក្បាល និង បាត់ម៉ាស៊ីនស្កេនចំនួន០១គ្រឿងផងដែរ។

បានឃើញចម្លើយរបស់សាក្សីឈ្មោះ . . បានឆ្លើយនៅសមត្ថកិច្ចថា៖ កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុន ត្រលប់ទៅផ្ទះសំរាក ដោយខ្លួនបានចាក់សោរទ្វាក្រុមហ៊ុនត្រឹមត្រូវ។ លុះទៀបភ្លឺថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា នៅក្រុមហ៊ុនមានចោរចូលគាស់ទ្វា ពេលនោះខ្លួនក៏ប្រញាប់មកក្រុមហ៊ុន រួចទើបដឹងថាចោរលួចយកទូរដែក០១ នៅក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន។

បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និង នៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ០៣ម ១៥នាទី ខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃ ដោយលួចបានទូរដែកប្រាកដមែន។ មុនដំបូងឈ្មោះ ( ) បានយកម៉ូតូ០១គ្រឿងម៉ាកសេ១០០ក្បរ៉ង្វើសពណ៌ក្រហម គ្មានស្លាកលេខ ពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉ក ដឹករូបខ្លួន និង បក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ។ ពេលពួកខ្លួនធ្វើដំណើរមកដល់ម្តុំទួលស្វាយព្រៃ ក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោរនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូ ហើយខ្លួនក៏បានយកទុលឡឺវីសមកឆ្កឹះសោរសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោរទ្វាខាងក្នុង រួចនាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយ និងលួចយកបានទូរដែក០១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉ក ទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់ បានឃើញលុយដុល្លារជាច្រើន និង ឯកសារផ្សេងទៀត ហើយចែកលុយគ្នា ដោយខ្លួនទទួលបានប្រាំមួយពាន់ដុល្លារ ' រីឯឯកសារទាំងនោះត្រូវបានដុតចោល។ បន្ទាប់មកខ្លួនបានយកលុយចំនួនបួនពាន់

ដុល្លារទៅផ្ញើរនិងឈ្មោះ ហើយសល់ប៉ុន្មានខ្លួនទៅចាយវាយនិងចែកអ្នកជិតខាងនៅស្វាយរៀង។ លុះដល់ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម៉ោង០០នាទី រសៀល ពេលខ្លួនកំពុងអង្គុយលេង ជាមួយឈ្មោះ និង ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ខ្លួនពិតជាបានអោយម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែក ប្រាកដមែន។ មុនដំបូងនៅល្ងាចថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ បានទូរសព្ទមកខ្លួនអោយទៅយកគេនៅម្តុំផ្សារ អំពៅ ពេលនោះខ្លួនក៏បានជិះម៉ូតូម៉ាក ១០០ កូរ៉េឆ្អើស ពណ៌ក្រហម គ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្លួនជិះ រួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ។ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្លួន គឺម៉ូតូរបស់ខ្លួនមានប្រដាប់សណ្តោងរ៉ឺម៉កស្រាប់។ លុះព្រឹកឡើងថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល៧ម៉ោង០០នាទី ឈ្មោះ បានទូរស័ព្ទមកខ្លួនអោយយកមកម៉ូតូ និង បានឲ្យលុយមកខ្លួនចំនួនមួយលានរៀល។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម៉ោង០០នាទី ខ្លួនបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និង ឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់មានសមត្ថកិច្ចមកឃាត់រូបខ្លួន និង ឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលខណ្ឌការមនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស បានឆ្លើយនៅចៅក្រមស៊ើបសួរថា៖ ខ្លួនពិតជាបានចូលរួមប្រព្រឹត្តអំពើលួចគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ ក្នុងនោះមានឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ ហៅ ។ ពេលនោះពួកខ្លួនលួចបាន ទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ (ហ្រ៉ាំម៉ឺនដុល្លារអាមេរិកគត់) ហើយក៏បានចែកគ្នា ដោយរូបខ្លួនបានចំណែកចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិកគត់) លុយសល់ពីនោះ ទុកឲ្យបក្ខពួក៤នាក់ទៀតចែកគ្នា។ ចំណែកទូរដែកនោះ បានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ១៨៤៨៦ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨០៦ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៥១៦៣ ត.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥២៦ ត.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៨១២៨ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៨ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

37/4

. ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៨១២៣ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

. ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៩ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបញ្ជូនឲ្យឆ្លើយលេខ ២០៩១២ តព្រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

. ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៨១៣ តព្រ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាចាត់ឲ្យស៊ើបសួរផ្ទេរលេខ ១៨៤៨៩ តព្រ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស។

- របាយការណ៍របស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមការចុះស្រាវជ្រាវរកឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ពុំមានស្ថិតស្ថេរនៅនិងសាវតាគេនៅក្នុងមូលដ្ឋានមណ្ឌលទី៨នោះទេ។

- លិខិតជូនដំណឹង ឬជូនព័ត៌មានដល់តំណាងអយ្យការលេខ ២០៧៣៧ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធសំណុំរឿង ។

## យល់ឃើញថា

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងចម្លើយសារភាពរបស់ជនត្រូវចោទ ពេនភាពស៊ីសង្វាក់ទៅនឹងភស្តុតាងអាចបង្ហាញឲ្យឃើញថា ៖ ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និង ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើផ្លាះសោរទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ដើម្បីលួចយកប្រាក់របស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ ភេទប្រុស (គេចខ្លួន), ឈ្មោះ ភេទប្រុស (គេចខ្លួន) និង ឈ្មោះ ភេទប្រុស (គេចខ្លួន) គឺអំពើដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត តាមមធ្យោបាយផ្លាះសោទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ ដើម្បីមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសលួចមានស្ថានទម្ងន់ទោស និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ គឺជាអំពើសំរបសំរួលដើម្បីសម្រេចបាននូវសកម្មភាពក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិតតាមមធ្យោបាយផ្លាះសោទ្វារក្រុមហ៊ុន

ស៊ុហ្គាទេសចរណ៍ដើម្បីយកប្រាក់ធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២២ឆ្នាំ គឺជាអ្នកទទួលផលក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសទទួលផលចោរកម្ម និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

- ឈ្មោះ ភេទប្រុស អាយុ២៧ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជានីតិជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- ឈ្មោះ ភេទប្រុស <u>អាយុ១៧ឆ្នាំ</u> និង ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជា <u>អនីតិជន</u> ប៉ុន្តែមានលក្ខណៈសម្បត្តិយល់ដឹងពនល្មមក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ និង ឈ្មោះ ពីបទ៖លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា, ឈ្មោះ ភេទប្រុស ពីបទ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងឈ្មោះ ភេទស្រី ពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ុហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ។

- តាមលទ្ធផលស្រាវជ្រាវរបស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ រកពុំឃើញឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ស្ថិតស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤ ទេ។

- យោងតាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧១ និងមាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីចៅក្រមលើកលែងចោទប្រកាន់លើឈ្មោះ ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ដោយហេតុជនត្រូវចោទនេះពុំសាវតាជាពិពិតប្រាកដ។

## <u>ហេតុដូច្នេះ</u>

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច ៖

☑ បញ្ជូនជនត្រូវចោទឈ្មោះ

១. ... ភេទប្រុស អាយុ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>(ឃាត់ខ្លួន) ទៅជំនុំជម្រះ។

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ុហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤. ភេទស្រី អាយុ២២ឆ្នាំ (គេចខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និង មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

☑ លើកលែងចោទប្រកាន់

- ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ មករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី៦

# សាកផរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០១.ឯកស.សរ/១៤

## សារាចរ

## ស្ដីពី

## ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្ដីពីការដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ២២៣ ដល់ មាត្រា ២៣០ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តមិនទាន់បានល្អប្រសើរ។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមស៊ើបសួរ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-ត្រូវគិតអំពីវិធានការនៃការត្រួតពិនិត្យ និងឃ្លាំមើលដើម្បីធានាថា ជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។

ករណីនេះ ចៅក្រមស៊ើបសួរគប្បីចាត់តាំងបុគ្គលណាមួយដែលមានសមត្ថកិច្ច អាចជួយតាមឃ្លាំមើល និងធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ គប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

៣-ត្រូវផ្ដល់ដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះមួយច្បាប់ ឲ្យដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬគ្រប់បុគ្គលដែលត្រូវបានចាត់តាំងក្នុងមូលដ្ឋានដែលជនត្រូវចោទត្រូវទៅរស់នៅ ដើម្បីអនុវត្តកាតព្វកិច្ច ក្រៅពីជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

៤-ត្រូវណែនាំជនត្រូវចោទ ដែលត្រូវបានដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យយកដីកាសម្រេចនេះ ទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលត្រូវបានចាត់តាំង ក្នុងមូលដ្ឋានដែលខ្លួនត្រូវទៅរស់នៅ។

៥-ត្រូវពិចារណាលើរបាយការណ៍ ឬព័ត៌មានរបស់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបទប្បញ្ញត្តិ នៃមាត្រា ២២៧-២២៨-២២៩ និង ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ-ព្រះរាជអាជ្ញា**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ពិនិត្យឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការស្នើសុំដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-បន្ទាប់ពីទទួលបានដីកាបង្គាប់ ដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវចាត់វិធានការដូចខាងក្រោម៖

-ណែនាំជនត្រូវចោទអំពីរបៀបដែលត្រូវអនុវត្តកាតព្វកិច្ច ដូចបានកំណត់ក្នុងដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ

-ណែនាំដល់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរឲ្យត្រួតពិនិត្យ តាមដាននិងធ្វើរបាយការណ៍តាមការកំណត់ ។

៣-ក្នុងករណីចៅក្រមស៊ើបសួរ បង្គាប់ឲ្យជនត្រូវចោទទៅបង្ហាញខ្លួន នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវបង្គាប់ទៅអង្គភាពនោះឲ្យចាត់វិធានការដូចខាងក្រោម៖

-រៀបចំឲ្យមានសៀវភៅសម្រាប់ចុះវត្តមានជនត្រូវចោទ ដែលត្រូវមកបង្ហាញខ្លួនតាមការកំណត់របស់ចៅក្រមស៊ើបសួរ

-ចាត់ភ្នាក់ងាររបស់ខ្លួនឲ្យតាមឃ្លាំមើលសកម្មភាពរបស់ជនត្រូវចោទ ក្នុងការបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ជនត្រូវចោទ (វត្តមាន និងសកម្មភាព) ក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់ជូនទៅព្រះរាជអាជ្ញា។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អង្គ_វង្សវឌ្ឍនា

<u>ចម្លងជូន៖</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-តុលាការ និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០២ [illegible]/១៦

**សារាចរ**

**ស្តីពី**

**ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង**

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្តារពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្ការនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ដាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានា

ចម្លងជូន ៖
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :..០៣ [illegible]/១៤

**សារាចរ**

**ស្ដីពី**

**ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍**

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្ដីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់ មាត្រា ៧៥ មាត្រា ៩៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្ដីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្ដល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្ដល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

មហាវិថីសម្ដេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 . 023 217 841

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២៧..ខែ..[illegible]..ឆ្នាំ..២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

ចម្លងជូន ៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ ៦៧០ កសល.នាក./២៤

រាជធានីភ្នំពេញ,ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើរបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង រាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ថាកន្លងមកក្រសួងយុត្តិធម៌បានផ្តល់នូវរបមន្តនៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះ ដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតរបមន្តថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្តីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងរបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

– នៅផ្នែកខាងដើមនៃរបមន្តពុំមានអ្វីផ្លាស់ប្តូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័តមានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួ ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាស់ជរា។ល។ ក្នុងស្ថានភាពបែបនេះ បើអាចជៀសវាងបាន មិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសំរេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយប្រើគំរូតាមរបមន្តថ្មីនេះ។

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

1. ចំណុចលេខ១តូចនេះ: ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២តូចនេះ: ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្ដី។

3. ចំណុចលេខ៣តូចនេះ: ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤តូចនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្ដីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាងរបស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. សំអាងហេតុសេចក្ដីសម្រេច ៖

5. ចំណុចលេខ៥តូចនេះ: ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ: ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦តូច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ: នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយពន្យល់បង្ហាញពីសំអាងហេតុសំរាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិ៍ដូចខាងក្រោម៖

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីធាតុផ្សំ/ហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីធាតុផ្សំដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណៈគឺងរឹងគ្រប់គ្រាន់ ដើម្បីសម្រេចបានគោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

ចៅក្រមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន សំរាប់ប្រភេទនីមួយៗនៃរឿងក្តី។

| ប្រភេទនៃបទល្មើស និង មាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ + ៦ខែ |
| បទមជ្ឈិម - មាត្រា២០៩ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរគួរធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈិម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្ដាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

ផ្នែកបញ្ចប់នៃរូបមន្តនេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្ដឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ចាត់ចែងការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។/

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

ជូនភ្ជាប់ :

- គំរូរូបមន្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍

ដើម្បីជូនជ្រាប